N. 38-39
23.10.02

# ក

## មាតិកា

### I- ខុទ្ទកាល័យព្រះមហាក្សត្រ

#### ១. ព្រះរាជក្រឹត្យ


០៨-១០-២០០២ - ព្រះរាជក្រឹត្យនស/រកត/១០០២/២៨២ ស្តីពីការតែងតាំង លោក **ហាក់ ប៊ុនធឿន** ជា **ឧកញ៉ា** ៣០២៩


### II- រាជរដ្ឋាភិបាល

#### ១. អនុក្រឹត្យ


០៩-១០-២០០២ - អនុក្រឹត្យលេខ ១០៣ អនក្រ បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ៣០៣០

១២-១០-២០០២ - អនុក្រឹត្យលេខ ១០៤ អនក្រ.បក ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋម និង មត្តេយ្យ សិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ៣០៣៣

១៧-១០-២០០២ - អនុក្រឹត្យលេខ ១០៥អនក្រ.បកស្តីពីការប្រើប្រាស់ឯកជនភាវូបនីយកម្ម សហគ្រាសសា ធារណៈ ៣០៣៦

២១-១០-២០០២ - អនុក្រឹត្យលេខ ១០៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣០៣៨

០៩-១០-២០០២ - អនុក្រឹត្យលេខ ៤៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៤០

០៩-១០-២០០២ - អនុក្រឹត្យលេខ ៤៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៤១

០៩-១០-២០០២ - អនុក្រឹត្យលេខ ៤៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៤២

០៩-១០-២០០២ - អនុក្រឹត្យលេខ ៤៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៤៣

០៩-១០-២០០២ - អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៤៤

០៩-១០-២០០២ - អនុក្រឹត្យលេខ ៤៨៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ៣០៤៥

១១-១០-២០០២ - អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣០៤៦

១៤-១០-២០០២ - អនុក្រឹត្យលេខ ៤៨៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣០៤៧

១៧-១០-២០០២ - អនុក្រឹត្យលេខ ៤៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៤៨

១៧-១០-២០០២ - អនុក្រឹត្យលេខ ៤៩១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣០៤៩

១៧-១០-២០០២ - អនុក្រឹត្យលេខ ៤៩២ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ៣០៥០

១៧-១០-២០០២ - អនុក្រឹត្យលេខ ៤៩៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣០៥១

១៧-១០-២០០២ - អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ៣០៥២

38-39




១៧-១០-២០០២ - អនុក្រឹត្យលេខ ៤៩៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣០៥៣

១៨-១០-២០០២ - អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និង តែងតាំងមន្ត្រីរាជការ ៣០៥៤

១៨-១០-២០០២ - អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូស្នួល ៣០៥៥

១៨-១០-២០០២ - អនុក្រឹត្យលេខ ៤៩៨ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយក ចំការកៅស៊ូចំការអណ្តូង ៣០៥៦

១៨-១០-២០០២ - អនុក្រឹត្យលេខ ៤៩៩ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូមេមត់ ៣០៥៧

១៨-១០-២០០២ - អនុក្រឹត្យលេខ ៥០០ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូក្រែក ៣០៥៨

១៨-១០-២០០២ - អនុក្រឹត្យលេខ ៥០១ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូជុប ៣០៥៩

១៨-១០-២០០២ - អនុក្រឹត្យលេខ ៥០២ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូពាមជាំង ៣០៦០

១៨-១០-២០០២ - អនុក្រឹត្យលេខ ៥០៣ អនក្រ.តត ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូបឹងកេត ៣០៦១

២១-១០-២០០២ - អនុក្រឹត្យលេខ ៥០៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣០៦២

២១-១០-២០០២ - អនុក្រឹត្យលេខ ៥០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៣

២១ ១០ ២០០២ - អនុក្រឹត្យលេខ ៥០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៤

២១-១០-២០០២ - អនុក្រឹត្យលេខ ៥០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៥

២១-១០-២០០២ - អនុក្រឹត្យលេខ ៥០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៦

២១-១០-២០០២ - អនុក្រឹត្យលេខ ៥០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៧

២១-១០-២០០២ - អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៨

២២-១០-២០០២ - អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០៦៨ ស្ទួន


## ២. សេចក្តីសំរេច


០៩-១០-២០០២ - សេចក្តីសំរេចលេខ ៤៩ សសរ ស្តីពីការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំបុណ្យសពឯកឧត្តម **ម៉ែន យ៉េត** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៣០៦៩


## ៣. សារាចរណែនាំ


១០-១០-២០០២ - សារាចរណែនាំលេខ ១២ សរណន ស្តីពីការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ថ្វាយព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគំរប់ព្រះជន្ម ៨០ យាង ចូល ៨១ ព្រះវស្សា ៣០៧១

១០-១០-២០០២ - សារាចរណែនាំលេខ ១៣ សរណន ស្តីពីការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុកនិង ពិធីខួបអនុស្សាវរីយ៍លើកទី ៤៩ នៃទិវាបុណ្យឯក រាជ្យ ជាតិ ៣០៧៤

# III-ការងារបណ្តាក្រសួង

## ១~ពីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


០៩-១០-២០០២ - សេចក្តីណែនាំអនុវត្តលេខ ០០៩ សហវ.ឧហ ស្តីពីអាជ្ញាប័ណ្ណឆ្នោត ៣០៧៨

១១-១០-២០០២ - ប្រកាសអន្តរក្រសួងលេខ ៦៤៨ សហវស្តីពីការបង់ថ្លៃប្រើប្រាស់ផ្លូវសំរាប់យានយន្តគ្រប់ប្រភេទ ដែល ធ្វើចរាចរលើដងផ្លូវជាតិលេខ ៤ ៣០៨៤

១៥-១០-២០០២ - សេចក្តីជូនដំណឹងលេខ ០២៥ សហវ.ពដ ចំពោះ ក្រុមហ៊ុនជំពាក់បំណុលពន្ធហើយបាត់ខ្លួនរកមិនឃើញ ៣០៨៧

១៨-១០-២០០២ -សេចក្តីជូនដំណឹងលេខ ០២៦ សហវ.ពដ ចំពោះ ក្រុមហ៊ុនជំពាក់បំណុលពន្ធហើយបាត់ខ្លួនរកមិនឃើញ ៣០៩៣


## ២~ ធនាគារជាតិនៃកម្ពុជា


១៧-១០-២០០២ - ប្រកាសលេខ ធ ៧-០២-២០៣ ប្រក ស្តីពីនីតិវិធីជាបទដ្ឋានសំរាប់សកម្មភាពកែតម្រូវបន្ទាន់ចំពោះគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ៣១០០

២១១០-២០០២ - ប្រកាសលេខ ធ ៧-០២-២០៦ ប្រក ស្តីពីនីតិវិធីជាបទដ្ឋានសំរាប់ការកំណត់អត្តសញ្ញាណនៃការសំអាតប្រាក់ នៅគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ៣១០៩


## ៣~ ពីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ


១៨-១០-២០០២ - សារាចរលេខ ០០២ ស.រ ៣១១៦


## ៤~ ពីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា


១៧-១០-២០០២ - ប្រកាសលេខ ៧៦៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ពាមត្រែងស្ថិតនៅក្នុងឃុំក្តីដូងស្រុកស្ទឹងសែន ខេត្ត កំពង់ធំ ៣១១៨

១៧-១០-២០០២ - ប្រកាសលេខ ៧៧០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ភ្នំព្រឹក ស្ថិតនៅក្នុងឃុំពេជ្រចិន្តាស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង ៣១១៩

១៧-១០-២០០២ - ប្រកាសលេខ ៧៧១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ តាក្រាមស្ថិតនៅក្នុងឃុំតាក្រាម ស្រុកបាណន់ ខេត្ត បាត់ដំបង ៣១២០

១៧-១០-២០០២ - ប្រកាសលេខ ៧៧២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ពាមឯកស្ថិតនៅក្នុងឃុំពាមឯកស្រុកឯកភ្នំ ខេត្ត បាត់ដំបង ៣១២១

១៧-១០-២០០២ - ប្រកាសលេខ ៧៧៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ គាស់ក្រឡស្ថិតនៅក្នុងឃុំគាស់ក្រឡ ស្រុក គាស់ក្រឡ ខេត្ត បាត់ដំបង ៣១២២

១៧-១០-២០០២ - ប្រកាសលេខ ៧៧៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន អម្ពរវ៉ែន ជំនីក ស្ថិតនៅក្នុងឃុំ ជំនីក ស្រុកក្រូចឆ្មារ ខេត្ត កំពង់ចាម ៣១២៣

១៧-១០-២០០២ - ប្រកាសលេខ ៧៧៥អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " សូបិណ " ទៅជាវិទ្យាល័យ " សូបិណ " ស្ថិតនៅក្នុងឃុំរាមអណ្តើក ស្រុកគីរីវង់ ខេត្ត តាកែវ ៣១២៤

# ព្រះរាជក្រឹត្យ

នស / រកត / ១០០២/ ២៨៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត ខិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ឈាក់ ម៉ូនធឿន

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០២
ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**

លេខៈ ៧០៩ច.ល

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

ពារ-០៧-១០.០០៧៩៩ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ ១៣ ឆ្នាំ២០០២
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បាមឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈ វិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ជូ សេដារុធ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០២
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ" " UNIVERSITY OF TECHNOLOGY, PHNOM PENH " ហៅកាត់ជា ភាសាខ្មែរ " ស.ប.ភ " និង

ហៅកាត់ជា ភាសាអង់គ្លេស "U.T.P.P" ។ សាកលវិទ្យាល័យនេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំងគោល ស្ថិតនៅអាគារលេខ ១៩ ផ្លូវលេខ ៣៨០ សង្កាត់ បឹងកេងកង ១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ និង ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ។

**មាត្រា ៣ :** សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញមាន :

១- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង ពត៌មានវិទ្យា

២- មហាវិទ្យាល័យ ពាណិជ្ជកម្ម និង ទេសចរណ៍

៣- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម

៤- មហាវិទ្យាល័យ មនុស្សសាស្ត្រ និង សិល្បៈ

៥- មហាវិទ្យាល័យ នីតិសាស្ត្រ

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ឬ កិរិត ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និង មានក្រុមប្រឹក្សាសិក្សាមួយសំរាប់ពិនិត្យផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុត បានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

សាកលវិទ្យាល័យ ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសនិស្សិតអោយចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវ ការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។

- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិតនិងឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះត្រូវបាន ផ្តល់អោយដោយសាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណី សាកលវិទ្យាល័យនេះបំពេញ និង អនុវត្តបានតាមគោលការណ៍កំនត់របស់ក្រសួង អប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យបច្ចេកវិទ្យាភ្នំពេញ មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិតាមអនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីមុខការ"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ១០៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលចេនាសម្ព័ន្ធនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

**មាត្រា១.-**

ត្រូវបានកែសម្រួលចេនាសម្ព័ន្ធនាយកដ្ឋានបឋម និងមត្តេយ្យសិក្សា ជាពីរនាយកដ្ឋាន គឺ នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ចំណុះអគ្គនាយកដ្ឋានអប់រំ នៃ ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា២ .** –

នាយកដ្ឋាននីមួយៗ មានមុខងារ និង ភារកិច្ចដូចខាងក្រោម ៖

**ក. នាយកដ្ឋានបឋមសិក្សា**

-អភិវឌ្ឍអប់រំបឋមសិក្សា សំរាប់ការអប់រំសំរាប់ទាំងអស់គ្នា

-លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំបឋមសិក្សារយៈពេលវែង មធ្យម ខ្លី

-កែលំអការអប់រំបឋមសិក្សា ដើម្បីធានាការចូលរៀនប្រកបដោយសមធម៌ និងគុណភាពអប់រំ ប្រកបដោយប្រសិទ្ធភាព

-កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍការអប់រំបឋមសិក្សា

-គ្រប់គ្រង និង ត្រួតពិនិត្យដំណើរការសិក្សានៅគ្រប់គ្រឹះស្ថានបឋមសិក្សារដ្ឋ និង ឯកជន លើការងាររដ្ឋបាល និងបច្ចេកទេស

-តាមដានត្រួតពិនិត្យ និងកែលំអការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ

-សិក្សាសំណើសុំបង្កើត បើក និងទទួលស្គាល់សាលាបឋមសិក្សារដ្ឋ និងឯកជន និងសំណើបង្រៀន ថ្នាក់ពីរពេល ថ្នាក់គួប

**ខ. នាយកដ្ឋានអប់រំកុមារតូច**

-អភិវឌ្ឍអប់រំកុមារតូច (០-៦ ឆ្នាំ) សំរាប់ការអប់រំសំរាប់ទាំងអស់គ្នា

-លើកទិសដៅកសាងផែនការអភិវឌ្ឍអប់រំកុមារតូច រយៈពេលវែង មធ្យម ខ្លី ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងសហគមន៍

-កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រងនិង អភិវឌ្ឍវិស័យអប់រំកុមារតូច

-គ្រប់គ្រង និងត្រួតពិនិត្យថ្នាក់ និង សាលាមត្តេយ្យសិក្សា ទាំងរដ្ឋ និងឯកជន លើការងាររដ្ឋបាល និងបច្ចេកទេស

-ជំរុញការអភិវឌ្ឍមត្តេយ្យសហគមន៍ ទារកដ្ឋាន និង ជំរុញគោលការណ៍អប់រំសហគមន៍ (ម្តាយ) ដើម្បីធានាថែទាំកុមារ ទាំងសុខភាព ទាំងបញ្ញា ដោយសហការជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និង សហគមន៍

-តាមដានត្រួតពិនិត្យ និងកែលំអ ការអនុវត្តកម្មវិធីសិក្សា បច្ចេកទេសគរុកោសល្យ

-សិក្សាសំណើសុំបង្កើត បើក និងទទួលស្គាល់សាលាមត្តេយ្យសិក្សារដ្ឋ និងឯកជន និងសំណើផ្សេងៗ ពាក់ព័ន្ធមត្តេយ្យសិក្សា និងទារកដ្ឋាន

**មាត្រា៣ .-**

នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការ មួយរូប រឺ ច្រើនរូបតាមការចាំបាច់ ។

**មាត្រា៤ .-**

ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់ នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u>** :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៦ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១០៥ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់គណនី

## ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

៙ ✧ ៙

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញអនុក្រឹត្យលេខ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១ :** អនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើង តាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ លើមុខសញ្ញា ចំណាយសំរាប់បុរេប្រទានជូនសាលាក្រុងភ្នំពេញ ដើម្បីទូទាត់ថ្លៃដី នៅភូមិទួលជង្រុក សង្កាត់ត្រពាំងក្រសាំង ខ័ណ្ឌដង្កោ សំរាប់ផ្ទេរលំនៅដ្ឋានប្រជាពលរដ្ឋ ចេញពីតំបន់ប៊ុលឌិញ រាជធានីភ្នំពេញ ដែលមានទឹកប្រាក់សរុប ចំនួន ១៨៤.៨៨៦,២២ ដុល្លារអាមេរិក ។ ចំពោះទឹកប្រាក់ដែលត្រូវចំណាយពិតប្រាកដ នឹងត្រូវធ្វើការទូទាត់តាមក្រោយ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្ដីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្ដីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៥.០០០ លានរៀល ( ប្រាំពាន់លានរៀលគត់ ) ពី ជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** — **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៤៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **អ៊ុន យុទ្ធី** ប្រធានក្រុមហ៊ុនបូរីកម្មករ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ វត្តអង្គញាត ក្នុងឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំណាយអស់ទឹកប្រាក់ចំនួន ១៦.៣៣២ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រភេទ និង ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាជួយកសាង បណ្ណាល័យ កុដិ និង សាលាឆាន់ នៅវត្តអង្គសូឃ្លាំង ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ដូចមាននាមខាងក្រោម ៖

**ក_មេដាយមាសស្ថាបនាជាតិ :**

- ព្រះតេជគុណ **សោ កុយ** ចៅអធិការវត្តអង្គសូឃ្លាំង បច្ច័យ ២៨.៩៦៤ USD

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

- លោក **មូសា ម៉ូរូមេ** ថវិកា ៥.៦០០ USD

**មាត្រា ២** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៤៧៤...អន.ក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងខេត្តកណ្តាល ដូចមាននាមខាងក្រោម ÷

១- លោក **ស៊ុត តារា** ប្រធាននាយកដ្ឋានកាំកុងត្រូល បានជួយកសាងព្រះវិហារ កុដិ និង សាលារៀន នៅវត្តចន្ទបូរីវង្ស ឃុំសំរោង ស្រុកពញាឮ ចំណាយអស់ទឹកប្រាក់ ៣៥.០០០ USD ។

២- លោកស្រី **ពៀ ប៉ាហ្គានី** ( PIA PAGANI ) នៅប្រទេសស្វីស បានជួយកសាងអគារ ០២ ខ្នង រួមទាំងបំពាក់បរិក្ខារគ្រប់គ្រាន់ ជូនមន្ទីរពេទ្យជ័យជំនះ ចំណាយអស់ទឹកប្រាក់ ៦២.០០០ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:.....៥៧៤.....អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៨ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងព្រះវិហារ វត្តអង្គបក្សី ឃុំជាំងទង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ÷

| | | | | | |
|---|---|---|---|---|---|
| ១- លោក | **សន** | **កុសល** | នៅខេត្តកោះកុង | ថវិកា | ១.០០០ USD |
| ២- លោក | **សារ៉ក់** | **សារឿន** | នៅក្រុងភ្នំពេញ | ថវិកា | ១.០០០ USD |
| ៣- ឧបាសិកា | **គង់** | **វ៉ាន់** | នៅប្រទេសបារាំង | ថវិកា | ១.៥០០ USD |
| ៤- លោក | **សែម** | **មឿន** | នៅក្រុងភ្នំពេញ | ថវិកា | ១.០០០ USD |
| ៥- លោកស្រី | **ឌី** | **ផាន់ណារ** | នៅក្រុងភ្នំពេញ | ថវិកា | ១.០០០ USD |
| ៦- លោក | **ភាក់** | **កើន** | នៅប្រទេសអូស្ត្រាលី | ថវិកា | ១.០០០ USD |
| ៧- លោក | **ហេង** | **ហឿន** | នៅខេត្តកោះកុង | ថវិកា | ១.០០០ USD |
| ៨- លោក | **សុខ** | **ជឿន** | នៅក្រុងភ្នំពេញ | ថវិកា | ១.០០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៨៦ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គលេខាធិការកាកបាទក្រហមកម្ពុជា

### ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនអង្គការ **MAP** និង តំណាងអង្គការនេះ ចំនួន ០៣ រូប ដែលបានជួយដល់វិស័យសុខាភិបាល និងអប់រំ នៃព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងភ្នំពេញ ខេត្តកណ្តាល និង ខេត្តកំពង់ចាម សរុបទឹកប្រាក់ចំនួន ១៦០.០០០ USD ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ**

១-អង្គការ **Médecine Aide et Présence** ( MAP ) នៅប្រទេសបារាំង

២-លោកវេជ្ជបណ្ឌិត **Jacques Devant** ប្រធានអង្គការ MAP

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១-លោកស្រី **Nicole Bourret** អនុប្រធានអង្គការ MAP

២-លោកស្រី **Monique Devant** មន្ត្រីអង្គការ MAP

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការកាកបាទក្រហមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៨៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **ផេង ស៊ុនហេង** អត្តលេខ ០៧៥៥ អនុប្រធាននាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន ។

២- លោកវរសេនីយ៍ទោ **ឌឹម ណារិទ្ធ** អត្តលេខ ០៥៧៧ អនុប្រធាននាយកដ្ឋានផែនការ-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣- លោកវរសេនីយ៍ទោ **ភួង ម៉ាលិយ** អត្តលេខ ០៦៨៥ អនុប្រធានសេនាធិការដ្ឋាន ។

៤- លោកវរសេនីយ៍ទោ **ឆាយ គីមខឿន** អត្តលេខ ០៦៧៧ អនុប្រធានសេនាធិការដ្ឋាន ។

៥- លោកវរសេនីយ៍ទោ **ស្វាយ ចាន់ដា** អត្តលេខ ០៨៣១ អនុប្រធាននាយកដ្ឋានបណ្តុះ-បណ្តាល និងវិក្រឹតការ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ១៣ ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៨៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០២ គ្រឿង ជូនអង្គភាព និង មេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អក្នុងការដឹកនាំ បង្ក្រាបទប់ស្កាត់ ចាប់វត្ថុបុរាណ ដូចមានរាយនាមខាងក្រោមនេះ ÷

១ - **បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ**

២ - លោកវរសេនីយ៍ឯក **រ័ត្ន ស្រ៊ាង** មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ១៣ ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ចំនួន ០២ គ្រឿង ជូនលោកសាស្ត្រាចារ្យជប៉ុន ចំនួន ០២ រូប ដែលបានខិតខំអនុវត្តអស់ពីកម្លាំងកាយចិត្ត នូវកិច្ចព្រមព្រៀង និង សហប្រតិបត្តិការ ជាមួយក្រសួងយុត្តិធម៌ ក្នុងការកសាងសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកប ដោយលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ÷

១-លោកសាស្ត្រាចារ្យ **ម៉ូរីហ្ស៊ីម៉ា អាគីអូ** ( MORISHIMA AKIO ) ប្រធានគណៈ - កម្មាធិការ នាយកនៃគំរោង

២-លោកសាស្ត្រាចារ្យ **តាកេហ្ស៊ីតា ម៉ូរីអូ** ( TAKESHITA MORIO ) ប្រធានក្រុម សាស្ត្រាចារ្យជប៉ុន

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនឧបាសិកា **ជៃ ឡឿម** សប្បុរសជនខ្មែរ នៅរដ្ឋម៉ូដេស្តូ សហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងសាលាធម្មសភា ០១ ខ្នង ជីកស្រះ ០២ កន្លែង និងធ្វើរបងវត្តគាស់ក្រឡចំនួន ០១ ខ្សែ នៅក្នុងស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់សរុបចំនួន ៧៨.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

HI,MD,LCN.023

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**មាត្រា១ :** ត្រូវបានតែងតាំងលោក **ហង់ ឌុល** បច្ចុប្បន្នជំនួយការផ្ទាល់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន ជំនួសលោក **អ៊ុម ស៊ីសាវដា** ដែលត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

III,MD,LCN.023

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៧. អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានផ្លាស់លោក **អុប ស៊ីសាវដា** បច្ចុប្បន្នអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន អោយមកបំរើការងារនៅក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

III,MD,LCN.023

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩៣ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានតែងតាំងលោក **ថៃ វណ្ណា** បច្ចុប្បន្នលេខាធិការផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ជំនួសលោក **ឆុង នីន** ដែលត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

III,MD,LCN.023

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៩៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានផ្លាស់លោក **ឆុង ឆឹន** បច្ចុប្បន្នអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន អោយមកបំរើការងារនៅក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០២
**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៩៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៩ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូសួល ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១** : ផ្ទេរភារកិច្ចលោក **ហេង សារ៉ាត់** បច្ចុប្បន្នប្រធានអគ្គនាយកចំការកៅស៊ូសួល អោយមកជាអគ្គនាយករង អគ្គនាយកដ្ឋានចំការកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូចំការអណ្តូង ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១** : ផ្ទេរភារកិច្ចលោក **ចាន់ ហ៊ិត** បច្ចុប្បន្នប្រធានអគ្គនាយកចំការកៅស៊ូចំការអណ្តូង អោយមកជាអគ្គនាយករង អគ្គនាយកដ្ឋានចំការកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៩៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូស្នួល

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៩ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូស្នួល ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១** : តែងតាំងលោក ម៉ិច សុវណ្ណ ជាប្រធានអគ្គនាយកចំការកៅស៊ូស្នួល សំរាប់អាណត្តិទី ២ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៩៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូចំការអណ្តូង

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូចំការអណ្តូង ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ស ម្រេ ច**

**មាត្រា ១** : តែងតាំងលោក **លឹម ស៊ុនលាង** ជាប្រធានអគ្គនាយកចំការកៅស៊ូចំការអណ្តូង សំរាប់អាណត្តិទី ២ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៩៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូមេមត់

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៣ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូមេមត់ ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១** : តែងតាំងលោក **ណោ ម៉ារឌី** ជាប្រធានអគ្គនាយកចំការកៅស៊ូមេមត់ សំរាប់អាណត្តិទី ២ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៨០០ អនក្រ បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូក្រែក

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៥ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូក្រែក ជាគ្រឹះស្ថានសាធារណៈបាទលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១** : តែងតាំងលោក សៀក ពិសិដ្ឋ ជាប្រធានអគ្គនាយកចំការកៅស៊ូក្រែក សំរាប់អាណត្តិទី ២ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :៥០១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូជុប

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៤ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូជុប ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ :** តែងតាំងលោក **ម៉ក់ គឹមហុង** ជាប្រធានអគ្គនាយកចំការកៅស៊ូជុប សំរាប់អាណត្តិទី ២ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៩០២ អនក្រ.តក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូពាមជាំង

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៦ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូពាមជាំង ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១** : តែងតាំងលោក ម៉ែន ស៊ីផាន់ ជាប្រធានអគ្គនាយកចំការកៅស៊ូពាមជាំង សំរាប់អាណត្តិទី ២ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩០៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងប្រធានអគ្គនាយកចំការកៅស៊ូបឹងកេត
****
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ / អនក្រ.បក / ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូបឹងកេត ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈជាសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១** : តែងតាំងលោក ស៊ឹម វណ្ណា ជាប្រធានអគ្គនាយកចំការកៅស៊ូបឹងកេត សំរាប់អាណត្តិទី ២ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥០៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធានជួយកសាងសាលាបាលី កុដិ របងវត្ត ក្លោងទ្វារ ផ្លូវ ក្នុងវត្តអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ដែលមានរាយនាមដូចខាងក្រោម ÷

១-ព្រះតេជគុណ **នូ សុធា** ចៅអធិការវត្តអរិយក្សត្រ បច្ច័យ ១៥.៧០០ USD

២-លោក **សាក់ សារិទ្ធិ** នៅរាជធានីភ្នំពេញ ថវិកា ១២.៣០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៥០៥...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកជំទាវ **ឡុង ស** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយស្ថាបនាផ្លូវលំ មួយខ្សែ ប្រវែង ៦.៩៩៣ ម៉ែត្រ រួមទាំងដាក់លូកាត់ផ្លូវចំនួន ០៩ កន្លែង និង លូភ្លោះ ០២ កន្លែង ក្នុងមូលដ្ឋាន ឃុំព្រៃរំដេង ស្រុកគីរីវង្ស ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ៣២.០០០ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥០៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី MARIKO OKAMURA ប្រធានអង្គការ ASAC ដែលបានធ្វើអំណោយអគារសិក្សា ០២ ខ្នង រួមទាំងបំពាក់សម្ភារៈសិក្សាគ្រប់គ្រាន់ជូនប្រជាពលរដ្ឋ ឃុំព្រៃអំពក ស្រុកគីរីវង្ស ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ៥៤.៣០០ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥០៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៥ រូប ដែលបានផ្តល់ថវិកាសំរាប់ជួយកសាងសាលារៀន ស្ពាន ផ្លូវលំ ស្រះ អណ្តូងទឹក និង សង់ផ្ទះជូនប្រជាជនក្រីក្រ នៅក្នុងស្រុកបាទី ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់សរុបចំនួន ២០៣.៧៣១ USD ដូចមានរាយនាមខាងក្រោម ÷

១- លោកស្រី **អូសាណៃ មីអិកុ** ប្រធានអង្គការ JHP នៅប្រទេសជប៉ុន
២- លោក **អ៊ីម៉ា គីយូស៊ី** ប្រធានអង្គការ JHP ប្រចាំនៅកម្ពុជា
៣- លោក **រ៉ូឡូស** ( ROLOF ) អង្គការស្ពានមិត្តភាពកម្ពុជា-ហូឡង់
៤- លោកស្រី **ទិនិច** ( TINEKE ) អង្គការស្ពានមិត្តភាពកម្ពុជា-ហូឡង់
៥- លោក **ម៉ានិច នាមមីជ័រ** ( MARNIX NIEMEIGER ) អង្គការស្ពានមិត្តភាពកម្ពុជា-ហូឡង់

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ....៥០៨....អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឈៅ ធួក** និងលោកស្រី **មាស ស៊ីថន** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងកុដិ ០១ ខ្នង ប្រគេនព្រះសង្ឃវត្តចារ ក្នុងឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ៣១.៥០០ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៩ ៣ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥០៩ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជនចំនួន ០៤ រូប ដែលបានបរិច្ចាគធនធានជួយកសាងសាលារៀន ផ្លូវ របងវត្ត ស្រះទឹក ក្នុងវត្តអង្គខ្ទា ឃុំនិទាប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម ÷

១-ព្រះតេជគុណ **ផៃ ទ្រី** ចៅអធិការវត្តអង្គខ្ទា បច្ច័យ ១១.៣០០ USD

២-ព្រះតេជគុណ **កុយ ធាន** គង់នៅសហរដ្ឋអាមេរិក បច្ច័យ ១៥.៤៥០ USD

៣-លោក **កុយ សុខ** អ្នកស្រី **តែ ស៊ុនឡាង** នៅសហរដ្ឋអាមេរិកថវិកា ១៨.២៦០ USD

៤-លោកស្រី **ឈឹម ឡាក់** នៅសហរដ្ឋអាមេរិក ថវិកា ១៥.៤៩៧ USD

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ ៩ ៧ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥១០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ធំ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ស៊ី ឃុនសេង** សប្បុរសជននៅសហរដ្ឋអាមេរិក ដែលបានធ្វើអំណោយជាថវិកាចំនួន ១០.៣៨៩ USD សំរាប់ជួយកសាង ផ្ទះ ០៦ ខ្នង អណ្តូងទឹក ១០ , ស្រះទឹកនៅវត្តជាយសំពៅ និង បំពាក់សំភារៈក្នុងបណ្ណាល័យវិទ្យាល័យរស្មីសោភ័ណ នៅក្នុងស្រុកប្រាសាទសំបូរ និង ស្រុកស្ទោង ខេត្តកំពង់ធំ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ ១០ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្វាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្វាបនាជាតិ** ចំនួន ០៤ គ្រឿង ជូនឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និង មន្ត្រីអង្គការមនុស្សធម៌ ដែលបានបរិច្ចាគធនធានចូលរួមកសាងសមិទ្ធផលនានាលើវិស័យសិក្សាធិការ នៅរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ÷

១-ឯកឧត្តម **GOTARO OGAWA** ឯកអគ្គរាជទូតជប៉ុន ថវិកា ២៣៦.២៣២ USD

២-លោកស្រី **MIEKO OSANAI** ប្រធានអង្គការ **J.H.P** ថវិកា ២៩.៩៥៣ USD

៣-លោក **JOHN WISSER** ប្រធានមូលនិធិ **DON BOSCO** ថវិកា ៨០.០០០ USD

៤-លោក **លឹម ធុន្ធី** ប្រធានអង្គការជួយសង្គ្រោះជនក្រីក្រ ថវិកា ២៥.០០០**USD**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាល - ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤៩...ស.ស.រ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម ម៉ែន យ៉េត រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរ និង ការងារចាំបាច់

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការចំរុះមួយ ដើម្បីរៀបចំបុណ្យសពឯកឧត្តម **ម៉ែន យ៉េត** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១_អ្នកអង្គម្ចាស់ | ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ | ប្រធាន |
| ២_ឯកឧត្តម | អ៊ុក សុជាតិ | អនុប្រធាន |
| ៣_ឯកឧត្តម | ជា គាន | អនុប្រធាន |
| ៤_ឯកឧត្តម | សេង លីមនៅ | សមាជិក |
| ៥_ឯកឧត្តម | ប៊ុន សំ | សមាជិក |
| ៦_ឯកឧត្តម | យូ ស៊ីនឡុង | សមាជិក |
| ៧_ឯកឧត្តម | ជា សុខុម | សមាជិក |
| ៨_ឯកឧត្តម | ហ៊ុល ផានី | សមាជិក |
| ៩_ឯកឧត្តម | ឃឹម សារិទ្ធ | សមាជិក |
| ១០_ឯកឧត្តម | ម៉ប់ សារិន | សមាជិក |

| | | |
|---|---|---|
| ១១_ឯកឧត្តម | ទុយ គឿន | សមាជិក |
| ១២_ឯកឧត្តម | ជឹង ឈង | សមាជិក |
| ១៣_ឯកឧត្តម | ឥត សារ៉ាត់ | សមាជិក |
| ១៤_ឯកឧត្តម | តែ គុយស៊ាង | សមាជិក |
| ១៥_លោក | បួន លីមហេង | សមាជិក |
| ១៦_លោក | គង់ សារ៉ាន់ | សមាជិក |
| ១៧_លោក | គីម សុផាណា | សមាជិក |

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ច :

_ទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម **ម៉ែន យ៉េត** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អោយបានល្អប្រសើរ ស្របតាមប្រពៃណីជាតិ ។

_រៀបចំកម្មវិធីលំអិតសំរាប់បុណ្យសព ពិធីការ ទទួលភ្ញៀវជាតិ អន្តរជាតិ ដែលត្រូវអញ្ជើញគោរពវិញ្ញាក្ខន្ធសព រៀបចំវិយោគកថា និងឯកសារផ្សេងៗដែលចាំបាច់ ។

_រៀបចំពិធីបូជាបូជាសពតាមប្រពៃណីសាសនា និងប្រពៃណីជាតិ ដោយសហការជិតស្និទ្ធជាមួយគ្រួសារសព ។

_ដោះស្រាយថវិកាសំរាប់បំរើការងាររៀបចំពិធីបុណ្យសព ។

_រៀបចំក្បួនដង្ហែសព និងពិធីបូជាសពអោយល្អប្រសើរ ។

_គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការមួយចំនួនទៀត តាមតំរូវការចាំបាច់ ដើម្បីជាជំនួយការ ។

_គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

_សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៣** : ទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ_អន្តរជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាម សេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ_កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧ សរណន

# សារាចរណែនាំ
# ស្តីពី
## ការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា គម្រប់ព្រះជន្ម ៨០ យាងចូល ៨១ ព្រះវស្សា

ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ គឺជាអាយុវឌ្ឍនមង្គលមួយដ៏ល្អប្រសើរថ្លៃថ្លារបស់ប្រជារាស្ត្រខ្មែរ ដែលប្រារព្ធឡើង ដើម្បីសំដែងនូវកតញ្ញូតាធម៌ចំពោះព្រះមហាករុណាទិគុណ ថ្វាយព្រះពរសព្ទសាធុការ និងថ្វាយមហាកុសលចំពោះ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាព្រះអង្គមគ្គុទ្ទេសក៍ដ៏ឆ្នើម និងជាព្រះបិតាឯករាជជាតិ ផ្សះផ្សាបង្រួបបង្រួមជាតិ ទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះសុខមាលភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និងព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ របស់ប្រជារាស្ត្រខ្មែរយូរអង្វែងតរៀងទៅ ។

ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ខេត្ត-ក្រុង និងប្រជាពលរដ្ឋទូទាំងប្រទេស តែងបានប្រារព្ធព្រះរាជពិធីបុណ្យចំរើនព្រះជន្មថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ក្នុងរយៈពេល ៣ថ្ងៃ គឺថ្ងៃទី ៣០-៣១ ខែ តុលា និងថ្ងៃទី ០១ ខែ វិច្ឆិកា តាមប្រពៃណីជាតិ និងប្រពៃណីសាសនា ។

ឆ្នាំនេះ នាឱកាសដ៏នក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចំរើនព្រះជន្មរបស់ព្រះអង្គ គម្រប់ព្រះជន្ម ៨០ យាងចូល ៨១ ព្រះវស្សា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវសារាចរណែនាំដូចតទៅនេះ :

១- ប្រគល់ភារកិច្ចជូនក្រសួងព្រះបរមរាជវាំង និងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីសក្ការៈ ឱ្យបានសមស្រមទៅនឹងប្រពៃណីជាតិ និងប្រពៃណីសាសនា ។

២- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំតុបតែងលំអ រចនាដោយភ្លើងពណ៌ តាំងព្រះឆាយាលក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** មានពាក្យស្លោកថ្វាយព្រះពរ និងសារថ្វាយព្រះពរ ព្រមទាំងបំផុសប្រជារាស្ត្រ អបអរសាទរដោយមានដោតទង់ជាតិគ្រប់គេហដ្ឋាន និងបដាពាក្យស្លោក ។

៣- គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម **ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង** ក្នុងក្របខ័ណ្ឌខេត្ត-ក្រុងរបស់ខ្លួន ដោយមានមន្ត្រីសង្ឃ ថ្នាក់ខេត្ត-ក្រុង មន្ត្រីរាជការថ្នាក់ខេត្ត-ក្រុង មន្ទីរនានាជុំវិញខេត្ត-ក្រុង-ខ័ណ្ឌ-ស្រុក អ្នកមុខអ្នកការ ចូលរួមឱ្យបានឱឡារិក និងមានរៀបចំសារថ្វាយព្រះពរផង ។

៤- ក្រសួងពត៌មាន ត្រូវណែនាំចាត់តាំងឱ្យបណ្តាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន តាមដានយកពត៌មាន ធ្វើការផលិតផ្សព្វផ្សាយព្រះរាជជីវប្រវត្តិ ស្នាព្រះហស្ត **ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង** ឱ្យបានទូលំទូលាយ ។

៥- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈ និងចម្រៀង បុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តសប្បាយ នៅតាមទីសាធារណៈទាំងបីថ្ងៃ ដើម្បីចូលរួមអបអរសាទរក្នុងទិវាដ៏នក្ខត្តឫក្សនេះ ។

៦- ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យសហការការពារសន្តិសុខរបៀបរៀបរយ សណ្តាប់ធ្នាប់សង្គម បំរើការរៀបចំព្រះរាជពិធីនេះ តាមសំណូមពរ ធានាសេចក្តីសុខក្សេមក្សាន្ត និងភាពសប្បាយរីករាយជូនប្រជាពលរដ្ឋយើង ។

៧- ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសម្ភារៈ និងថវិកាសម្រាប់បំរើការរៀបចំព្រះរាជពិធីបុណ្យនេះ ឱ្យបានសមស្រប និងទាន់ពេលវេលា ។

៨- គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវមានផែនការបែងចែកតាមក្រសួង រដ្ឋលេខាធិការដ្ឋាន មន្ទីរ ស្ថាប័ន អំពាវនាវសប្បុរសជន អង្គការក្រៅរដ្ឋាភិបាល អង្គការមនុស្សធម៌ ក្រុមហ៊ុនឯកជន ជួយឧបត្ថម្ភជា សម្ភារៈ ថវិកា គ្រឿងឧបភោគ បរិភោគផ្សេងៗ ចុះសួរសុខទុក្ខ ដល់យុទ្ធជនរបួស មានជម្ងឺ កំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ យុទ្ធជនពិការ នៅតាមមណ្ឌលពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យ គ្មានទីពឹង ដើម្បីសំដែងមនោសញ្ចេតនា អាណិតស្រឡាញ់ លើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ចាត់តាំងអនុវត្តស្មារតីសារាចរនេះ សំរេចបានលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងប្រពៃណីជាតិយើង ./.

រាជធានីភ្នំពេញ . ថ្ងៃទី១០ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោកសម្រាប់ប្រើប្រាស់ ក្នុងព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៨០ យាងចូល ៨១ ព្រះវស្សា

១- សូមថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា មានព្រះរាជសុខុមាលភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

២- សូមថ្វាយព្រះពរសម្តេចឪ និងសម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៣- ជយោ ! សម្តេចឪ និងសម្តេចម៉ែ ។

៤- ជយោ ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា ។

៥- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ ។

៦- ជយោ ! ព្រះរាជាណាចក្រកម្ពុជា ។

៧- ជាតិ សាសនា ព្រះមហាក្សត្រ ។

៨- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍ ។

៩- ជយោ ! សម្តេចព្រះបិតាឯករាជជាតិ ។

១០- ជយោ ! សម្តេចព្រះបិតាសន្តិភាព ផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៣ សរណន

# សារាចរណែនាំ
# ស្តីពី
## ការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក និងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៩ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា

✳ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក គឺជាព្រះរាជពិធីដ៏ល្អប្រពៃរបស់ប្រជាជាតិយើង ដែលបង្ហាញពីសាមគ្គីភាពទូលំទូលាយ ទឹកចិត្តជាអ្នកធ្វើបុណ្យកុសល គោរពដឹងគុណ ស្រឡាញ់ភាពសុខក្សេមក្សាន្ត សប្បាយរីករាយ ពិងភាពម៉ឺងម៉ាត់ ថាមពលព្យ្សាវក្លា អំណត់ព្យាយាម និងឆន្ទៈប្រយុទ្ធស្រួចស្រាល់របស់ប្រជាពលរដ្ឋយើង ក្នុងការការពារឯករាជ្យជាតិ ការពារបូរណភាពទឹកដី ការពារទ្រព្យសម្បត្តិ កេរដំណែល ប្រពៃណីវប្បធម៌ និងកិត្តិយសថ្លៃថ្នូររបស់ជាតិ ។

ឆ្នាំនេះ ព្រះរាជពិធីបុណ្យអុំទូក នឹងត្រូវប្រព្រឹត្តទៅរយៈពេល ៣ ថ្ងៃ គឺថ្ងៃ ១៤-១៥ កើត និងថ្ងៃ ១ រោច ខែ កត្តិក ត្រូវនឹងថ្ងៃទី ១៨-១៩ និង ២០ ខែ វិច្ឆិកា ឆ្នាំ ២០០២ គឺជាការបើកឱកាសជូនប្រជារាស្ត្រ ចូលរួមថែរក្សានូវប្រពៃណីជាតិរបស់ខ្លួន ដែលជាប់ទាក់ទងទៅនឹងប្រវត្តិពិធីសមយុទ្ធ នៃកំលាំងសាមគ្គីកងទ័ពជើងទឹករបស់យើង ក្នុងបុព្វហេតុការពារមាតុភូមិ និងសំដែងនូវមនោសញ្ចេតនា ប្រកបដោយកតញ្ញូតាធម៌ ចំពោះព្រះមហាករុណាទិគុណនៃព្រះរតនត្រ័យ ពពួកទេវតា និងវត្ថុស័ក្តិសិទ្ធិ ដែលបានគាំពារនិងជួយឧបត្ថម្ភឱ្យវិស័យកសិកម្មជាតិ មានការរីកចំរើនរុងរឿង ព្រមទាំងជាឱកាសបួងសួង សុំឱ្យបារមីនៃព្រះពុទ្ធជាម្ចាស់ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ បន្តជួយឧបត្ថម្ភវិស័យកសិកម្មនារដូវខាងមុខ ឱ្យទទួលបានជោគជ័យ និងទិន្នផលខ្ពស់ជាងបណ្តាឆ្នាំកន្លងទៅទៀតផង ។

✳ ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៤៩ នៃទិវាបុណ្យឯករាជ្យជាតិ នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ ដើម្បីសំដែងមនោសញ្ចេតនាអបអរសាទរ រំលឹកទិវាប្រវត្តិសាស្ត្រ ដែលកំលាំងមហាសាមគ្គីជាតិទាំងមូល ដណ្តើមបានទាំងស្រុងមកវិញ ពីអាណានិគមនិយមបារាំង នាឆ្នាំ ១៩៥៣ នូវឯករាជ្យជាតិដ៏ពិតប្រាកដ ក្រោមព្រះរាជបូជនីយកិច្ចដ៏ថ្លៃថ្លានៃ**ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីចាត់តាំងរៀបចំពិធីបុណ្យទាំងពីរនេះ ឱ្យបានសមរម្យ ស័ក្តិសមទៅនឹងអត្ថន័យដ៏ជ្រាលជ្រៅដូចបានបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវសារាចរណែនាំអនុវត្តដូចតទៅ ÷

ដេ

## ១.អំពីព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក :

- គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងពាក់ព័ន្ធ រាជធានីភ្នំពេញ និង ខេត្ត-ក្រុង ចាត់តាំងរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាប នៅវេទិកាព្រះរាជពិធី បុណ្យអុំទូក មុខព្រះបរមរាជវាំង ក្នុងរយៈពេល ៣ ថ្ងៃ តាមប្រពៃណីជាតិ ប្រពៃណីសាសនា ដោយ មានចាត់តាំងក្រសួង ស្ថាប័នមួយចំនួន រចនាតុបតែងជាប្រទីប មានអុចកាំជ្រួចភ្លឺទៀន មានតាំងភ្លើងពណ៌ រៀងរាល់យប់ នៅរាជធានីភ្នំពេញ។

- ដើម្បីឱ្យការរៀបចំពិធីបុណ្យនេះ កាន់តែអធិកអធមឡើង រាជរដ្ឋាភិបាលអនុញ្ញាតឱ្យមានការរៀបចំ បណ្តែតប្រទីប របស់ក្រុមហ៊ុនឯកជន ដែលស្ម័គ្រចិត្តចូលរួម ដោយឡែក ក្រោយពីប្រទីបរបស់រាជរដ្ឋាភិបាល បណ្តែតដង្ហែចេញដំណើរ ជាស្ថាពរហើយ ។

- ត្រូវមានផែនការណែនាំលំអិតជាក់ស្តែង ស្តីពីល័ក្ខខ័ណ្ឌទាំងឡាយ នៃការជ្រើសរើសទូក ង ដែលត្រូវចូលរួមប្រណាំង ដោយត្រូវកំណត់ទូកអុំ-ទូកចែវ ឱ្យបានច្បាស់លាស់ និងត្រូវធ្វើសេចក្តីអំពាវនាវ សប្បុរសជន បណ្តាក្រុមហ៊ុនឯកជននានា ឱ្យជួយឧបត្ថម្ភជា សម្ភារៈ ថវិកា សម្រាប់ជូនជារង្វាន់ដល់កីឡាករ កីឡាការិនីអុំទូក និងបំរើការផ្សព្វផ្សាយ ថែរក្សា នូវប្រពៃណីជាតិដ៏ល្អនេះ ។

- ខេត្ត-ក្រុង ដែលមានទូកង ចូលរួមប្រណាំង ត្រូវធ្វើការសាកល្បងហ្វឹកហាត់ចម្រាញ់ជ្រើសរើសទូក ដែលមានចំណាត់ថ្នាក់ជាទូកលឿនរបស់ខេត្ត-ក្រុង ក្នុងចំនួនសមស្រប សម្រាប់ចូលរួមប្រណាំងនៅរាជធានីភ្នំពេញ ។

## ២.អំពីបុណ្យឯករាជ្យជាតិ :

- ត្រូវចាត់តាំងរៀបចំពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៩ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ក្នុងកម្រិតរូបភាពមួយដ៏មហោឡារិក ស័ក្តិសមទៅនឹងកិត្តិយសប្រទេសជាតិ ដោយមានចាត់តាំងមីទ្ទិញមហាជនមួយ នៅបរិវេណវិមានឯករាជ្យ មានព្រះសង្ឃ មានថ្នាក់ដឹកនាំជាតិ មន្ត្រីរាជការ ស៊ីវិល យោធា នគរបាល លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ប្រជាពលរដ្ឋ និងភ្ញៀវអន្តរជាតិ ចូលរួមឱ្យបានច្រើនកុះករ និងមានចាត់តាំងពិធីដុតទៀនជ័យ ដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធ ព្រមទាំងមានបង្ហោះប៉េងប៉ោង លែងព្រាបជានិមិត្តរូបនៃការសុំសុខសន្តិភាពផង និងពិធីពន្លត់ទៀនជ័យ ដោយមានរូបភាព ចាត់តាំងកំលាំងមហាជនចូលរួមឱ្យបានច្រើនកុះករ ដូចថ្ងៃដុតទៀនជ័យដែរ ។

- ខេត្ត-ក្រុង ត្រូវចាត់តាំងពិធីមីទ្ទិញមហាជន និងពិធីគោរពវិញ្ញាណក្ខន្ធ នៅតាមទីកន្លែងដ៏សមគួរ តាមការជាក់ស្តែងរបស់ខេត្ត-ក្រុងនីមួយៗ និងបំផុសមហាជន ប្រជាជន ដោតទង់ជាតិ ដុតគោមបំភ្លឺពេលយប់ ដើម្បីអបអរសាទរ ។

- គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវរៀបចំកម្មវិធីសម្រាប់ថ្នាក់ដឹកនាំក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចុះសួរសុខទុក្ខ យុទ្ធជនរបួស មានជម្ងឺ កំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ យុទ្ធជនពិការនៅតាមមណ្ឌលពិការ កុមារកំព្រា នៅតាមមណ្ឌលកុមារកំព្រា ដោយមាននាំអំណោយជួយឧបត្ថម្ភ និងធ្វើការណែនាំឱ្យគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចងបដា ពាក្យស្លោក ដោតទង់ជាតិ ទង់ក្ងោក និងតុបតែងលំអភ្លើងពណ៌ឱ្យបានឱឡារិក ។

- ត្រូវបូកសរុបគម្រោងថវិកាចំណាយលំអិត ដែលក្រសួងពាក់ព័ន្ធបានលើកឡើងក្នុងស្មារតី សន្សំសំចៃ ផ្លែប្រមិតខ្ពស់ ផ្ញើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច រួចហើយត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីការអនុវត្តចំណាយទាំងអស់ ។

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈ និងចំរៀង បុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្ត នៅតាមទីសាធារណៈ អបអរសាទរក្នុងពិធីបុណ្យទាំងពីរខាងលើ ។

- ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសម្ភារៈ និងថវិកាសម្រាប់បំរើការរៀបចំពិធីបុណ្យទាំងពីរខាងលើ ឱ្យបានសមស្រប និងទាន់ពេលវេលា ។

- ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ត្រូវត្រៀមលក្ខណៈចាត់តាំងការពារសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គម ចរាចរ តាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព សេចក្តីសុខក្សេមក្សាន្ត និងសេចក្តីសប្បាយរីករាយជូនប្រជាពលរដ្ឋយើង ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ ខេត្ត-ក្រុង ចាត់តាំងអនុវត្តស្មារតីសារាចរនេះ ឱ្យបានសំរេចលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរ ហើយធ្វើរបាយការណ៍បូកសរុបជូនរាជរដ្ឋាភិបាល ៕

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ ១៧ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត-ក្រុង
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោកសម្រាប់ប្រើប្រាស់
# ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក
# និងពិធីបុណ្យឯករាជ្យជាតិ ឆ្នាំ ២០០២

១- សូមថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា មានព្រះរាជសុខុមាលភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

២- សូមថ្វាយព្រះពរសម្តេចឪ និងសម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៣- ជយោ ! សម្តេចឪ និងសម្តេចម៉ែ ។

៤- អបអរសាទរយ៉ាងក្លៀវក្លា ខួបអនុស្សាវរីយ៍លើកទី ៤៩ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា " ០៩-១១-១៩៥៣ - ០៩-១១-២០០២ "

៥- ចងចាំជានិច្ច នូវព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជាតិដ៏ឧត្តុង្គឧត្តម របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ។

៦- ជយោ ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា ។

៧- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ ។

៨- ជយោ ! ព្រះរាជាណាចក្រកម្ពុជា ។

៩- ជាតិ សាសនា ព្រះមហាក្សត្រ ។

១០- អបអរសាទរ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ។

១១- អបអរសាទរ លទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

១២- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍ ។

១៣- ជយោ ! សម្តេចព្រះបិតាឯករាជ្យជាតិ ។

១៤- ជយោ ! សម្តេចព្រះបិតាសន្តិភាព ផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ 008 សហវ.អ.ព

# សេចក្តីណែនាំអនុវត្ត
# អាជ្ញាប័ណ្ណឆ្នោត

អនុលោមតាមសេចក្តីជូនដំណឹងលេខ ១១២៥ សជណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃ ទី ០១ ខែ សីហា ឆ្នាំ ២០០២ ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជូសមុខដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( ក្រសួង) ផ្តល់អាជ្ញាប័ណ្ណជូន លោក **BENJAMIN JOSEPH PERRY** ជនជាតិអាមេរិកជានាយកក្រុមហ៊ុនហ្គោល ដេន វីន វីន (ខេមបូឌា) អ៊ីន **GOLDEN WIN WIN (CAMBODIA) INC** ដែលមានអាសយដ្ឋានផ្ទះលេខ ៩ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីធ្វើអាជីវកម្មឆ្នោតនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមលក្ខខ័ណ្ឌ ដូចខាងក្រោម :

## ប្រការ ១ : ការផ្តល់អាជ្ញាប័ណ្ណ

អ្នកទទួលអាជ្ញាប័ណ្ណត្រូវបានអនុញ្ញាតអោយធ្វើអាជីវកម្មឆ្នោត នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមលក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ២ ហើយត្រូវផ្តល់និងថែរក្សាប្រព័ន្ធឆ្នោតតាមគុណភាព និងកំរិតអន្តរជាតិ ។ ប្រភេទឆ្នោតដែលអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបានអនុញ្ញាតអោយធ្វើអាជីវកម្ម គឺប្រភេទឆ្នោតកោស និងឆ្នោតឡូតូ ៦/៤៩ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះប្រភេទឆ្នោតដែលបានទទួលការអនុញ្ញាតហើយ តែអ្នកទទួលអាជ្ញាប័ណ្ណមិនបានធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មហើយ ប៉ុន្តែបានផ្អាកសកម្មភាពលើស ពីរយៈពេល ០៤ ខែ ប្រភេទឆ្នោតនោះ នឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ ។ មុននឹងធ្វើអាជីវកម្ម អ្នកទទួលអាជ្ញាប័ណ្ណត្រូវផ្តល់នូវការត្រួតពិនិត្យលើកំរិតបច្ចេកទេស និងទីតាំងនៃការលេងល្បែងឆ្នោតឡូតូពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយបានរយៈពេលមួយខែជាមុនសិន ។ អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវគោរពច្បាប់ឆ្នោតនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន ហើយនិងបទបញ្ញត្តិ ឬប្រកាសផ្សេងៗទៀត ដែល[illegible] ហើយព្រមទាំងអនុវត្តអោយបានស្របតាមបទបញ្ញត្តិ ឬប្រកាសផ្សេងៗ ដែលដាក់ចេញដោយ[illegible] នីមួយៗដែលទាក់ទងទៅនឹងទំរង់ការ មាតិការ រចនាបទ និងតំលៃនៃសន្លឹកឆ្នោត ។

## ប្រការ ២ : រយៈពេលនៃអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណនេះត្រូវផ្តល់អោយមានរយៈពេល ៣ឆ្នាំ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខាលើអាជ្ញាប័ណ្ណ ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ មានបំណងចង់បន្តរយៈពេលអាជ្ញាប័ណ្ណជាថ្មីទៀត ត្រូវដាក់ពាក្យសុំការអនុញ្ញាតពីក្រសួងមិនអោយលើសពីរយៈពេល ៣ខែ មុនកាលបរិច្ឆេទបញ្ចប់អាជ្ញាប័ណ្ណ ។ ការផ្តល់អោយបន្តអាជ្ញាប័ណ្ណនេះជាថ្មី គឺជាសិទ្ធិរបស់ក្រសួង ។

## ប្រការ ៣ : ប្រាក់ចំណូលដែលត្រូវបង់ជូនរដ្ឋ

អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបង់ចំណូលចូលរតនាគារជាតិតាមចំនួនភាគរយនៃផលរបរដុល លើការលក់សន្លឹកឆ្នោតតាមអត្រាដូចខាងក្រោម :

| | |
|---|---|
| ឆ្នាំទី ១ ដល់ឆ្នាំទី ៥ | ១០% |
| ឆ្នាំទី ៦ ដល់ឆ្នាំទី ១០ | ១២% |
| ឆ្នាំទី ១១ ដល់ឆ្នាំទី ១៥ | ១៣% |
| ឆ្នាំទី ១៦ ដល់ឆ្នាំទី ២៥ | ១៥% |

ប្រាក់ចំណូលនេះ ត្រូវបង់ចូលរតនាគារជាតិជារៀងរាល់ខែយ៉ាងយូរត្រឹមថ្ងៃទី១០នៃខែបន្ទាប់ ។ ចំពោះប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបាន ត្រូវទុកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីត្រួតពិនិត្យលើប្រាក់ចំណូលនេះអោយបានត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ) និងអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើការត្រួតពិនិត្យរួមគ្នានូវចំនួនសន្លឹកឆ្នោត ឬ លិខិតយុត្តិការនៃការធ្វើអាជីវកម្មឆ្នោត ឡូតូ (ដែលមានសញ្ញាសំគាល់អនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ) មុននឹងដាក់លក់និងសន្លឹកឆ្នោតនៅសល់ ។

## ប្រការ ៤ : ពន្ធអាករផ្សេងៗ

ក្រៅពីការបង់ប្រាក់ចំណូល ដូចមានចែងក្នុងប្រការ៣ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបង់ពន្ធអាករផ្សេងៗទៀតទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ៥ : របាយការណ៍ប្រចាំខែ

អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវថែរក្សាទុកដាក់យ៉ាងហ្មត់ចត់នូវឯកសារផ្សេងៗ ដែលទាក់ទងទៅនឹងការធ្វើអាជីវកម្មឆ្នោត ។ នៅពេលបង់ចំណូលក្នុងខែនីមួយៗ អ្នកទទួលអាជ្ញាប័ណ្ណត្រូវផ្តល់នូវរបាយការណ៍លំអិតបញ្ជាក់ពីប្រាក់ចំណូលដុលដែលបានមកពីការធ្វើអាជីវកម្មឆ្នោតក្នុងខែមុនមកក្រសួងអោយបានមុនថ្ងៃទី ០៥នៃខែបន្ទាប់ ។ របាយការណ៍នេះ ត្រូវបញ្ជាក់ថាជាការពិត និងត្រឹមត្រូវដោយអ្នកតំណាងម្នាក់ដែលអ្នកទទួលអាជ្ញាប័ណ្ណផ្តល់សិទ្ធិ ។

## ប្រការ ៦ : របាយការណ៍ប្រចាំឆ្នាំ

ក្នុងរយៈពេល៣ខែ ក្រោយពីការបញ្ចប់ឆ្នាំនីមួយៗ អ្នកទទួលអាជ្ញាប័ណ្ណត្រូវផ្តល់អោយ[illegible] បញ្ជីគណនេយ្យ/

នៃឆ្នាំសារពើពន្ធដែលត្រូវបានត្រួតពិនិត្យ ដោយស្នងការគណនីមកពីក្រុមហ៊ុនត្រួតពិនិត្យគណនេយ្យដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទទួលស្គាល់ ។ របាយការណ៍របស់ស្នងការគណនីមួយច្បាប់ត្រូវផ្ញើជូនក្រសួង ។

### ប្រការ ៧ : ការត្រួតពិនិត្យបញ្ជី

រយៈពេលប្រាំពីរថ្ងៃ ក្រោយពីការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬក្នុងករណីចាំបាច់ក្រសួងមានសិទ្ធិចុះធ្វើការត្រួតពិនិត្យសៀវភៅបញ្ជីស្ទាម និង ឯកសារផ្សេងៗ ទៀតដែលជាប់ទាក់ទងទៅនឹងការធ្វើអាជីវកម្មឆ្នោត ។ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ដើម្បីធ្វើការត្រួតពិនិត្យបញ្ជីស្ទាម និង ឯកសារផ្សេងៗ របស់អ្នកទទួលអាជ្ញាប័ណ្ណ ។ ក្រសួងមានសិទ្ធិជួលគណនេយ្យករ ដើម្បីចូលរួមក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងមានសិទ្ធិថតចម្លងនូវឯកសារផ្សេងៗ តាមតំរូវការក្នុងការត្រួតពិនិត្យ ។

### ប្រការ ៨ : ការធ្វើអាជីវកម្មឆ្នោត

សន្លឹកឆ្នោតដែលដាក់លក់ដោយអ្នកទទួលអាជ្ញាប័ណ្ណត្រូវ :

ក-ផ្តល់នូវភាពត្រឹមត្រូវយុត្តិធម៌ និងស្មើភាពគ្នាក្នុងការទទួលរង្វាន់ចំពោះអ្នកទិញ ។

ខ-ផ្តល់យ៉ាងតិច ៥០% នៃចំណូលពីការលក់សន្លឹកឆ្នោត សំរាប់ជារង្វាន់ចំពោះអ្នកទិញ ក្រោយពីបានបង់ចំណូលចូលថវិកាដោយផ្អែកតាមអត្រាដែលបានកំណត់ ។

គ-ការចេញឆ្នោត ត្រូវចេញដោយស្ថិតក្រោមការត្រួតពិនិត្យនៃភាគីឯករាជ្យមួយនៃក្រុមហ៊ុនត្រួតពិនិត្យគណនេយ្យដែលមានការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឃ-លទ្ធផលនៃការចេញឆ្នោត ត្រូវចុះផ្សាយតាមសារពត៌មានណាមួយ ដែលកំពុងផ្សាយពត៌មានទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះសន្លឹកឆ្នោតជ័យលាភីត្រូវបើករង្វាន់ជូន ក្នុងរយៈពេល ៣០ថ្ងៃ និងត្រូវជូនដំណឹងអំពីលទ្ធផលនៃការបើករង្វាន់មកក្រសួង ។

ង-បានអនុវត្តស្របទៅតាមលក្ខខ័ណ្ឌ ដែលនឹងមានចែងក្នុងច្បាប់តាមដំណាក់កាលនីមួយៗ ។

### ប្រការ ៩ : ផ្នែកគណនីនៅរតនាគារជាតិ

អ្នកទទួលអាជ្ញាប័ណ្ណត្រូវតំកល់ប្រាក់រធានារង្វាន់របស់ខ្លួន នៅរតនាគារជាតិដើម្បីប្រើប្រាស់ក្នុងការទិញរង្វាន់ ឬបើកប្រាក់រង្វាន់ដល់ជ័យលាភីនីមួយៗនៅពេលដែលក្រុមហ៊ុនមានបញ្ហាហិរញ្ញវត្ថុមិនអាចដោះស្រាយបាន ឬក្រុមហ៊ុនក្ស័យធន ។ សាច់ប្រាក់ដែលត្រូវតំកល់នៅរតនាគារជាតិនេះគឺស្មើនឹង ៥០% នៃផលរបរដុលក្រោយពីបានបង់ចំណូលរតនាគារជាតិតាមអត្រាកំណត់ ។

### ប្រការ ១០ : ការផ្ទេរឈ្មោះ អ្នកចែកចាយ និងភ្នាក់ងារ

អ្នកទទួលអាជ្ញាប័ណ្ណមិនត្រូវផ្ទេរអាជ្ញាប័ណ្ណនេះ ទៅអោយភាគីណាមួយផ្សេងទៀត ដោយគ្មានការឯកភាពជា

លាយលក្ខណ៍អក្សរពីក្រសួងទេ ។ អ្នកទទួលអាជ្ញាប័ណ្ណមានសិទ្ធិជួលបុគ្គលិក និងបង្កើតដំណើរការបណ្តាញលក់សន្លឹកឆ្នោត នៅក្នុងតំបន់នីមួយៗដែលទទួលបានការអនុញ្ញាត ។

**ប្រការ ១១ : ការផាកពិន័យ**

-អ្នកទទួលអាជ្ញាប័ណ្ណ ខកខានមិនបានបង់ប្រាក់ចំនួនណាមួយ ( សារពើពន្ធ ចំណូលរតនាគារជាតិ និងប្រាក់តំកល់ធានារង្វាន់ ) ទៅក្រសួងតាមកាលកំណត់ ។ ការបង់ប្រាក់របស់អ្នកទទួលអាជ្ញាប័ណ្ណ ដែលបានធ្វើឡើងក្រោយកាលកំណត់ នឹងត្រូវទទួលការផាកពិន័យដូចមានចែងក្នុងច្បាប់សារពើពន្ធពីមាត្រា ទី ១២៥ ដល់មាត្រា ១៤០ ទៅតាមខ្លឹមសារសង្ខេបដូចខាងក្រោម :

ក.យឺតយ៉ាវ ០១ខែត្រូវពិន័យ១០%បូកការប្រាក់២%លើចំនួនទឹកប្រាក់មិនបានបង់ ឬចំនួនដែលបង់ខ្វះ ។

ខ.យឺតយ៉ាវច្រើនខែត្រូវពិន័យ ២៥% ទៅ ៤០% បូកនឹងការប្រាក់២%លើចំនួនប្រាក់មិនបានបង់ ឬចំនួនចំនួនដែលបង់ខ្វះ ។

-ចំពោះផលរបរដែលមិនបានប្រកាសមកក្រសួង នឹងត្រូវទទួលការផាកពិន័យ ១០ដង នៃចំនួនដែលមិនប្រកាស ។

-អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើលិខិតជូនដំណឹងមកក្រសួងស្តីពីការផ្អាកសកម្មភាពអាជីវកម្មចំនួន ១៥ថ្ងៃ មុនការផ្អាកសកម្មភាព ។ ក្នុងករណីជូនដំណឹងក្រោយការផ្អាកលើសពីចំនួន ០៣ថ្ងៃ ក្រុមហ៊ុនត្រូវរងទទួលការផាកពិន័យស្មើនឹង ១០ដង នៃចំណូលរតនាគារជាតិខែចុងក្រោយដែលបានបង់ហើយ ។

**ប្រការ ១២ : ការបញ្ឈប់សកម្មភាពអាជីវកម្ម**

ក្រសួងមានសិទ្ធបញ្ឈប់សកម្មភាពអាជីវកម្មរបស់អ្នកទទួលអាជ្ញាប័ណ្ណក្នុងករណី :

-អ្នកទទួលអាជ្ញាប័ណ្ណ ធ្វើសកម្មភាពប្រភេទល្បែងដែលគ្មានការអនុញ្ញាតក្នុងអាជ្ញាប័ណ្ណ គ្មានការអនុញ្ញាតបន្ថែមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមានការអនុញ្ញាតហើយ ប៉ុន្តែអនុវត្តខុសពីបទដ្ឋានបច្ចេកទេសដែលក្រសួងបានកំណត់ ។

-អ្នកទទួលអាជ្ញាប័ណ្ណ កំពុងធ្វើសកម្មភាពអាជីវកម្មជាមួយនឹងអាជ្ញាប័ណ្ណដែលអស់សុពលភាព ។ ក្រុមហ៊ុនអាចចាប់ផ្តើមធ្វើសកម្មភាពរបស់ខ្លួនឡើងវិញបន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណថ្មីពីក្រសួង ។

-ចំណូលអាជីវកម្មប្រចាំខែរបស់ក្រុមហ៊ុនមានកំរិតមិនសមស្របនឹងទំហំអាជីវកម្ម ។

**ប្រការ ១៣ : ការលុបចោលអាជ្ញាប័ណ្ណ**

ក្រសួងមានសិទ្ធិលុបចោលអាជ្ញាប័ណ្ណទៅតាមព្រឹត្តិការណ៍ និងដំណោះស្រាយទាំងឡាយ ដែលអ្នកទទួលអាជ្ញាប័ណ្ណពុំបានឆ្លើយតបក្រោយរយៈពេល ១៥ ថ្ងៃ ទៅនឹងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់ក្រសួង ដើម្បីដោះស្រាយទៅលើការមិនគោរព និង មិនអនុវត្តតាមលក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណដូចខាងក្រោម :

ក-អ្នកទទួលអាជ្ញាប័ណ្ណពុំបានចាប់ផ្តើមបើកធ្វើអាជីវកម្មក្នុងរយៈពេល ០៦ខែ (ប្រាំមួយខែ) គិតចាប់ពីខែដែលបានចេញអាជ្ញាប័ណ្ណ ។ ក្នុងករណីមានមូលហេតុសមស្រប និងច្បាស់លាស់ការពន្យាពេលបើក អាជីវកម្មអាស្រ័យលើការសំរេចរបស់ក្រសួង ។

ខ- អ្នកទទួលអាជ្ញាប័ណ្ណពុំបានអនុវត្តតាមលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ទៅតាមច្បាប់ឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា (ច្បាប់ដែលបានអនុម័តរួចនិងវិសោធនកម្មទៅតាមដំណាក់កាលនីមួយៗ)ឬមិនគោរពតាមការណែនាំផ្សេងៗរបស់ក្រសួង ។

គ- អ្នកទទួលអាជ្ញាប័ណ្ណផ្អាកសកម្មភាពអាជីវកម្មលើសពី ០២ខែ ដោយគ្មានមូលហេតុ ។

ឃ-អ្នកទទួលអាជ្ញាប័ណ្ណដំណើរការអាជីវកម្ម ដោយគ្មានតំកល់ប្រាក់ធានាសងរង្វាន់តាមការកំណត់របស់ក្រសួង ។

ង-មានការខុសគ្នាធំដុំណាមួយ រវាងរបាយការណ៍ប្រចាំខែដែលបានដាក់ជូនក្រសួង និងរបាយការណ៍ត្រួតពិនិត្យគណនីដែលបានរៀបចំឡើង ដើម្បីដាក់ជូនក្រសួងនាដំណាច់ឆ្នាំនីមួយៗ ។

ច- អ្នកទទួលអាជ្ញាប័ណ្ណខកខានមិនបានផ្តល់បញ្ជីវិភាគគណនី និងឯកសារផ្សេងៗដែលទាក់ទងនឹងការធ្វើអាជីវកម្មឆ្នោតតាមសេចក្តីត្រូវការរបស់ក្រសួង ។

ឆ- អ្នកទទួលអាជ្ញាប័ណ្ណផ្ទេរកម្មសិទ្ធិអាជ្ញាប័ណ្ណ ទៅអោយអ្នកផ្សេងទៀតដោយពុំមានការអនុញ្ញាត ។

ជ- អ្នកទទួលអាជ្ញាប័ណ្ណក្ស័យធនក្នុងការធ្វើអាជីវកម្ម ក្រសួងនឹងចេញបញ្ជាឱ្យបញ្ឈប់សកម្មភាពធ្វើអាជីវកម្ម និងធ្វើការទូទាត់បំណុល ហើយក្រសួងនឹងចាត់តាំងអ្នកចាត់ចែងការអោយទទួលបន្ទុកជំនួស ឬ កាន់កាប់ទ្រព្យសម្បត្តិរបស់អ្នកទទួលអាជ្ញាប័ណ្ណ ។

ឈ- ក្នុងអំឡុងឆ្នាំទី១ នៃរយៈពេលអាជ្ញាប័ណ្ណនេះ អ្នកទទួលអាជ្ញាប័ណ្ណមិនបានជំរុញ និងលក់សន្លឹកឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ។

ញ- អ្នកទទួលអាជ្ញាប័ណ្ណបានប្រព្រឹត្តិបទឧក្រិដ្ឋ ឬប្រព្រឹត្តិអំពើមិនស្របច្បាប់ណាមួយ ដែលក្រសួងយល់ថាជាទង្វើមិនសមស្របជាអ្នកកាន់អាជ្ញាប័ណ្ណ ។ បន្ទាប់ពីការលុបអាជ្ញាប័ណ្ណ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបញ្ឈប់ជាបន្ទាន់នូវការលក់សន្លឹកឆ្នោតលើទីផ្សារ និង សកម្មភាពធ្វើអាជីវកម្មឆ្នោតទៀត ហើយមិនត្រូវថាខ្លួនជាអ្នកកាន់អាជ្ញាប័ណ្ណឆ្នោតដែលបានចេញដោយក្រសួងឡើយ ។

## ប្រការ ១៤ : សេចក្តីជូនដំណឹង

សេចក្តីជូនដំណឹងណាមួយដែលបានចេញដោយក្រសួង និងចេញដោយអ្នកទទួលអាជ្ញាប័ណ្ណត្រូវ ធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកតំណាងស្របច្បាប់នៃភាគីពាក់ព័ន្ធដោយ : (១) ហុចជូនដល់ដៃ (២) ឬតាមប្រៃសណីយ៍ (៣) ឬទូរសារ ។ សេចក្តីជូនដំណឹងទាំងនេះ ចាត់ទុកថាបានទទួល : (១) ដោយមានបញ្ជាក់ពេលវេលានៃការទទួល ប្រសិនបើផ្តល់អោយផ្ទាល់ដៃ (២) ចុះហត្ថលេខាទទួលបើជាអនុសិដ្ឋ (៣) ឬនៅពេលដែលបានទទួលច្បាប់ចម្លងនៃសេចក្តីជូនដំណឹងនេះតាមទូរសារដោយសុវត្ថិភាពប្រសិនបើផ្ញើតាមទូរសារ ។

**ប្រការ ១៥ ៖ ច្បាប់គ្រប់គ្រងភាសា**

អាជ្ញាប័ណ្ណត្រូវបានគ្រប់គ្រង និងកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណត្រូវបានធ្វើឡើងជាពីរភាសា ៖ ខ្មែរ និងអង់គ្លេស ។ អត្ថបទភាសាខ្មែរជាអត្ថបទផ្លូវការនៃអាជ្ញាប័ណ្ណ ។

អាជ្ញាប័ណ្ណចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

ខ្ញុំបាទ BENJAMIN JOSEPH PERRY ជានាយក ក្រុមហ៊ុនសាជីវកម្ម Golden Win Win (Cambodia) Inc សូមសន្យា នឹងគោរពនូវរាល់ខ្លឹមសារ ដូចមានចែងក្នុងលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ និងបទបញ្ញត្តិផ្សេងៗ ទៀតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្នុងករណីដែលខ្ញុំមិនគោរពតាមនេះ ខ្ញុំបាទ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ។

ភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០២

ហត្ថលេខា

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤៨ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០២

# ប្រកាសអន្តរក្រសួង

ស្តីពី

## ការបង់ថ្លៃប្រើប្រាស់ផ្លូវសំរាប់យានយន្តគ្រប់ប្រភេទ ដែលធ្វើចរាចរលើផងផ្លូវជាតិលេខ៤

※※※※※

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យលេខ នស/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកត/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ,
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ,
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់អំពីប្រព័ន្ធហិរញ្ញវត្ថុ.
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩,
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០,
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០១,

- បានឃើញព្រះរាជក្រមលេខ នស កម ០១៩៦-០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន.
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ-បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន.
- បានឃើញកិច្ចព្រមព្រៀងសម្បទាន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០១ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន អេហ្សិត ឌីស្ទ្រីប៊្យូហ្សិន ស្តីពីការថែទាំជួសជុលផ្លូវជាតិលេខ៤.
- បានឃើញចំណាររបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០២ លើលិខិតលេខ ១៨៩៤ សក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០២ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន .
- បានឃើញលិខិតលេខ ១៥៦៨ សជណ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី.
- បានឃើញលិខិតលេខ ១៥៦៩ សជណ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី.
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៤ សសរ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន.
- តាមការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន.

## សំរេច

**ប្រការ១:** កំណត់បណ្តាយានយន្តគ្រប់ប្រភេទ ដូចមានចែងក្នុងប្រការ២ ដែលធ្វើចរាចរលើដងផ្លូវជាតិលេខ៤ ចាំបាច់ត្រូវបង់ប្រាក់ ជាប្រាក់រៀល ឬប្រាក់ដុល្លារ សំរាប់សេវាកម្មថែទាំ និងជួសជុលផ្លូវនេះ ។

**ប្រការ២:** កំណត់តំលៃយានយន្តគ្រប់ប្រភេទត្រូវបង់ ( មួយបញ្ជរបង់ប្រាក់ ) ដូចខាងក្រោម :

1- រថយន្តធុនធ្ងន់ដោយមានតណ្តោងរ៉ឺម៉កមិនគិតលើសពី 40ហ្វីត 6,30 ដុល្លារអាមេរិក

2- រថយន្តធុនធ្ងន់ដែលមានតួវែង មិនគិតលើសពី 20ហ្វីត 4,90 ដុល្លារអាមេរិក

3- រថយន្តធុនធ្ងន់ :

+ រថយន្តស៊ីទែនប្រេង 6,00 ដុល្លារអាមេរិក

+ រថយន្តលាតដឹកផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម 4,20 ដុល្លារអាមេរិក

+ រថយន្តបែន (ដឹកដី, ថ្ម, គ្រួស, ខ្សាច់) 2,50 ដុល្លារអាមេរិក

4- រថយន្តដឹកទំនិញធុនស្រាល :

+ រថយន្តដឹកទំនិញចាប់ពី : 3 តោន → 6 តោន 2,50 ដុល្លារអាមេរិក

+ រថយន្តដឹកទំនិញចាប់ពី : 2 តោន → ក្រោម 3 តោន 2,00 ដុល្លារអាមេរិក

+ រថយន្តដឹកទំនិញចាប់ពី : 1 តោន → ក្រោម 2 តោន 1,50 ដុល្លារអាមេរិក

5- រថយន្ត Bus 2,50 ដុល្លារអាមេរិក

6- រថយន្ត Mini Bus (12 កៅអី) [illegible],50 ដុល្លារអាមេរិក

7- រថយន្តតាក់ស៊ី 1,00 ដុល្លារអាមេរិក(ពុំទាន់យកថ្លៃផ្លូវ)

8- រថយន្តទេសចរគ្រួសារ 1,00 ដុល្លារអាមេរិក(ពុំទាន់យកថ្លៃផ្លូវ)

**ប្រការ៣:** រាល់យានយន្តគ្រប់ប្រភេទដែលធ្វើចរាចរលើដងផ្លូវជាតិលេខ៤ ត្រូវទទួលការផាកពិន័យអំពីការផ្ទុកលើសទម្ងន់ដោយអនុវត្តតាមច្បាប់ និងអនុក្រឹត្យដោយគ្មានការលើកលែង ។

**ប្រការ៤:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសាធារណការ និងដឹកជញ្ជូន គ្រប់ក្រសួង ស្ថាប័នខេត្ត-ក្រុង ដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីពេលដាក់អោយដំណើរការអាជីវកម្មជាផ្លូវការ តទៅ ។

**ប្រការ៥:** ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ នឹងត្រូវចាត់ទុកជានិរាករណ៍ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

រដ្ឋមន្ត្រី

ក្រសួងសាធារណការ និងដឹកជញ្ជូន

*កន្លែងទទួល:*

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រុមហ៊ុន អេហ្សិត
- ក្រុមហ៊ុនដឹកជញ្ជូន

"ដើម្បីជូនជ្រាបជាពត៌មាន"

- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ : ...០៩៥.... សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០០២

# សេចក្តីជូនដំណឹង

## ចំពោះ

## ក្រុមហ៊ុនជំពាក់បំណុលពន្ធហើយបាត់ខ្លួនរកមិនឃើញ

កន្លងមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញនូវសេចក្តីជូនដំណឹងលេខ ០២២ សហវ.ពដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ ដោយបានផ្សព្វផ្សាយតាមបណ្តាញសារពតិមាន ដើម្បីធ្វើការរំលឹកជាចុងក្រោយបង្អស់ ដល់លោក-លោកស្រី ជាប្រធានក្រុមហ៊ុនទាំងអស់ ដែលនៅជំពាក់បំណុលពន្ធរដ្ឋ សូមអញ្ជើញមកធ្វើការទូទាត់សងបំណុលពន្ធអោយបានចប់សព្វគ្រប់មុនថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០២ ជាកំហិត ។ មានក្រុមហ៊ុនមួយចំនួន បានបំពេញកាតព្វកិច្ចទូទាត់បំណុលពន្ធរួចហើយ ។ ប៉ុន្តែរហូតដល់ពេលនេះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសង្កេតឃើញថា មានក្រុមហ៊ុនមួយចំនួនដែលនៅជំពាក់បំណុលពន្ធរដ្ឋ ហើយបាត់ខ្លួនដោយបិទក្រុមហ៊ុនហើយបង្កើតក្រុមហ៊ុនថ្មី និង ក្រុមហ៊ុនមួយចំនួនទៀត បានផ្លាស់ប្តូរអាស័យដ្ឋានច្រើនលើកច្រើនសារ ដោយមិនផ្តល់ពតិមានដល់រដ្ឋបាលពន្ធដារ ហើយក្រុមហ៊ុនទាំងនោះនៅតែរឹងរូសមិនព្រមបំពេញកាតព្វកិច្ច ហើយមិនបានអញ្ជើញមកទំនាក់ទំនងធ្វើការដោះស្រាយទូទាត់បំណុលពន្ធ តាមសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខាងលើឡើយ ។

ជាថ្មីម្តងទៀតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងជាចុងក្រោយបង្អស់ដល់លោក-លោកស្រី ដែលជាប្រធាន អភិបាល ឬ បណ្ណាធិការដែលទទួលខុសត្រូវក្រុមហ៊ុន ដូចមានរាយនាមខាងក្រោមនេះ អញ្ជើញមកដោះស្រាយបំណុលពន្ធ នៅនាយកដ្ឋានពន្ធដារ មិនអោយហួសពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០២ ។ ករណីលោក-លោកស្រី មិនបានអញ្ជើញមកធ្វើការដោះស្រាយទូទាត់បំណុលពន្ធតាមការកំណត់ខាងលើនេះទេ លោក លោកស្រី នឹងត្រូវប្រឈមមុខវិធានការតឹងទារ និងបណ្តឹងចោទប្រកាន់តាមផ្លូវច្បាប់ជាធរមាន ។

ក្រុមហ៊ុនដែលបាត់ខ្លួនរកមិនឃើញ ហើយមិនបានអញ្ជើញមកដោះស្រាយទូទាត់បំណុលពន្ធរួមមាន :

| ល.រ | នាមករណ៍សហគ្រាស | អាស័យដ្ឋានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ | លេខអត្តសញ្ញាណកម្ម (TIN) | ការិយបរិច្ឆេទជំពាក់ពន្ធ | មុខរបរ | ឈ្មោះអ្នកគ្រប់គ្រង |
|---|---|---|---|---|---|---|
| ០១ | សេង ហុង | ៨១E₀ ផ.២៨៦ ស/កអូរឡាំពិក ខ.ចំការមន | ១០០០៩៩៣ | ១៩៩៥-១៩៩៦ | Imp Exp | តាន់ មុយស្រេង |
| ០២ | ហ៊ុន ហ៊ុន ត្រេឌីង ខេមបូឌា អាហរ័ណ នីហរ័ណ | ៧២៩E₀ ផ.៩៣ ស/កបឹងកេងកង១ ខ.ចំការមន | ១០០០៦០៤ | ១៩៩៤ | Imp Exp | អ៊ឹង លីម |
| ០៣ | ពន្លឺអង្គរពាណិជ្ជ អាហរ័ណ នីហរ័ណ | ២១៦ ផ.១៦៣ ស/កបឹងកេងកង១ ខ.ចំការមន | ១០០០៦១៥ | ១៩៩៤-១៩៩៥<br>១៩៩៦-១៩៩៧<br>១៩៩៨ | Imp Exp | ចាន់ ឡុង |
| ០៤ | ផុន ស៊ុយ ឆេមផាញ អាហរ័ណ នីហរ័ណ | ៤៩៣ ផ.៣១០ ស/កបឹងកេងកង២ ខ.ចំការមន | ១០០០៦៨១ | ១៩៩៥ | Imp Exp | អ៊ិន សុផុន |
| ០៥ | ហេង ហួត អារ័ណ នីហរ័ណ ដឹកជញ្ជូន | ៥១-៥៣ ផ.១២៦ ស/កផ្សារថ្មី១ ខ.ដូនពេញ | ១០០០៧៨០ | ១៩៩៥ | Imp Exp | ឈុន ហួត |
| ០៦ | គីម កៅ អាហរ័ណ នីហរ័ណ | ២៣៤ ផ.ព្រះសីហនុ ស/កបឹងកេងកង២ ខ.ចំការមន | ១០០០៨៤៦ | ១៩៩៥ | Imp Exp | ហា ស៊ុន |
| ០៧ | មេហ្គាម៉ែក្ស អ៊ិនធ័រណេស្សុណល | ៨១E₀ ផ.២១៥ ស/កផ្សារដេប៉ូ ខ.ទួលគោក | ១០០០៨៨០ | ១៩៩៥ | Imp Exp | តា រដ្ឋាភិរម្យ |
| ០៨ | ចាន់ ម៉េងគុយ អារ័ណ នីហរ័ណ កាស្សប៊ែរ | ៤៩ ផ.កម្ពុជាក្រោម ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០០០៩២៣ | ១៩៩៥-១៩៩៦<br>១៩៩៧-១៩៩៨<br>១៩៩៩-២០០០ | Imp Exp | ញឹម ភួង |
| ០៩ | ស៊ូ ហាក់ អាហរ័ណ នីហរ័ណ | ៥៥២ ផ.២ ស/កចាក់អង្រែក្រោម ខ.មានជ័យ | ១០០១១៧៦ | ១៩៩៩ | Imp Exp | លឹម ជាហ៊ុយ |
| ១០ | ហ្គោលដិនថាយដ៏ រោងចក្រកាត់ដេរ | ១៧៧១ ផ.២ ស/កចាក់អង្រែក្រោម ខ.មានជ័យ | ១០០១៨៩១ | ១៩៩៧-១៩៩៨ | Garment | លី យាង |
| ១១ | ឌានគ្រុប អិនធើណេស្សុណល ខេមបូឌា | ៩១ ផ.២៩៤ ស/កចតុមុខ ខ.ដូនពេញ | ១០០២០០១ | ១៩៩៤-១៩៩៥ | ដឹកជញ្ជូន | យូ វិនដាសាម |
| ១២ | ម៉ានីឡា | ៥៩A ផ.សុធារស ស/កទន្លេបាសាក់ ខ.ចំការមន | ១០០២៤៨៥ | ១៩៩៦-១៩៩៧ | Imp Exp | ឈាង វណ្ណាន |
| ១៣ | កាំប៉ិចស៊ីម និង ចែកចាយ | ៤៣៩ ផ.ព្រះមិន្ទូវង្ស ស/កបឹងព្រលិត ខ.៧មករា | ១០០២៥១៨ | ១៩៩៤ | Imp Exp | លឹម សំអាត |
| ១៤ | សណ្ឋាគារ បាការា | ៨៥A ផ.ព្រះនរោត្តម ស/កផ្សារកណ្តាល ខ.ដូនពេញ | ១០០២៦៧២ | ១៩៩៦ | | សុខ ហឿង |
| ១៥ | យ៉ូកូហាម៉ា បូឃី | ៦២៦E₀ ផ.កម្ពុជាក្រោម ស/កផ្សារដេប៉ូ២ ខ.ទួលគោក | ១០០៣៩៤៨ | ១៩៩៧-១៩៩៨ | ពាណិជកម្ម | ហេង អ៊ុយម៉េង |
| ១៦ | លឹម ផេងអាង អាហរ័ណ ណីហរ័ណ | ២៦ E₀ ផ.១៩៩ ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០០៣៩៥៩ | ១៩៩៧-១៩៩៨ | Imp Exp | យ៉េន សុខអៀង |
| ១៧ | ខេមអាស៊ី ត្រេឌីង | ៤៣ ផ.មុនីរ៉េត ស/កវាលវង់ ខ.៧មករា | ១០០៤១៩០ | ១៩៩៧ | | សុង អុង |
| ១៨ | ខេមបូឌា ប្លូប៊ីត អ៊ិនធើណេស្សុណល ហ្គាមិន | ៥២៤ ផ.២ ស/កចាក់អង្រែក្រោម ខ.មានជ័យ | ១០០៤២៩០ | ១៩៩៧ | Garment | លឹង ស៊ៀវស៊ុង |
| ១៩ | អីនយេគ្រុប អ៊ីមផត អ៊ិចផត ត្រង់ស្ពតសឺវិស | ២២៥ E₀ ផ.២៣០ ស/កផ្សារដើមគរ ខ.ទួលគោក | ១០០៤៥៣១ | ១៩៩៩ | Imp Exp<br>Transport | ឈឹម សុភន |
| ២០ | ហ័ងស៊្យ អាហរ័ណ នីហរ័ណ | ៤៩ ផ.៣៦៨ ស/កបឹងកេងកង៣ ខ.ចំការមន | ១០០៤៧១៨ | ១៩៩៩ | Imp Exp | ទិតអាន ចាន់រីយ៉ា |
| ២១ | រស្មីមុនីវត្ត | ផ.៦A ព្រែកលាប ឫស្សីកែវ | ១០០៤៩០៥ | ១៩៩៧-១៩៩៨ | Imp Exp | អេង អាង |
| ២២ | លាតវី អាហរ័ណ នីហរ័ណ | ១៤៨ ផ.ព្រះសីហនុ ស/កបឹងកេងកង១ ខ.ចំការមន | ១០២០៨១៣ | ១៩៩៤-១៩៩៥<br>១៩៩៦-១៩៩៧<br>១៩៩៨ | Imp Exp | ហុង គីមឡេង |

| | | | | | | |
|---|---|---|---|---|---|---|
| ២៣ | យូនីខេម អាហារ៉ណ នីហារ៉ណ | ២៦ ផ.១៩៩ ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០២១០៣៣ | ១៩៩៤ | Imp Exp | លឹម អេកខាយ |
| ២៤ | អ៊ុម៉ិក លីមីធីត | ១៥ ផ.ព្រះនរោត្តម ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០២១០៦៦ | ១៩៩៦ | សេវាយក ពតិមាន | ថៃ សេងឡុង |
| ២៥ | ធនាគារសន្តិភាព ពាណិជ្ជ | ៣៥០ ផ.២១៧ ស/កអូរឬស្សី២ ខ.៧មករា | ១០២១២៧៥ | ១៩៩៧-១៩៩៨ | ធនាគារ | គង់ ទ្រីវ |
| ២៦ | សាន ម៉ៅ កម្ពុជា | ១១ ផ.១៤៤ ស/កផ្សារកណ្តាល២ ខ.ដូនពេញ | ១០២១៤៨៤ | ១៩៩៥-១៩៩៦ ១៩៩៩ | ពាណិជកម្ម | ខុង ងៀប |
| ២៧ | សុភី អាហារ៉ណ នីហារ៉ណ សំណង់ | ១៨៦Eo ផ.៣០២ ស/កបឹងកេងកង១ ខ.ចំការមន | ១០២១៥៦១ | ១៩៩៤-១៩៩៥ ១៩៩៦ | អា/នី សំណង់ | លឹម សុភី |
| ២៨ | សំណង់ នីកាអភិវឌ្ឍន៍ | ៨១Eo ផ.១៥កែង១៣០ ស/កផ្សារចាស់ ខ.ដូនពេញ | ១០២១៦០៥ | ១៩៩៥ | សំណង់ | វង្ស វុទ្ធី |
| ២៩ | ប៉ែល ដុន (អាស៊ី) | ៤២ ផ.២៤០ ស/កចតុមុខ ខ.ដូនពេញ | ១០២១៦៥០ | ១៩៩៦ | អាហារ៉ណ នីហារ៉ណ | អឹន យ៉ាង |
| ៣០ | ពន្លឺកុមារ | ១៤៤ ផ.១២៨ ស/កទឹកល្អក់ ខ.ទួលគោក | ១០២១៦៨២ | ១៩៩៦-១៩៩៧ ១៩៩៨ | អាហារ៉ណ នីហារ៉ណ | ស៊ឹម រ៉ាស៊ី |
| ៣១ | ង៉ូវ ហុក អាហារ៉ណ នីហារ៉ណ | ៣៧៥Eo ផ.១២៨ ស/កមិត្តភាព ខ.៧មករា | ១០២១៧០៤ | ១៩៩៦-១៩៩៧ ១៩៩៨ | អាហារ៉ណ នីហារ៉ណ | ប៊ុន ធឿន |
| ៣២ | យូ អានតេង អ៊ីនធើប្រាយស៍ | ១៣ ផ.ពោធិកំបោរ ស/កវាលវង់ ខ.៧មករា | ១០២១៨៧០ | ១៩៩៥ | អាហារ៉ណ នីហារ៉ណ | វ៉ុយ សៀងឡេង |
| ៣៣ | ងូវ ជីវហុង កម្ពុជា អារ៉ណ នីហារ៉ណ | ២៨៨ ផ.២៧៤ ស/កអូរឡាំពិក ខ.ចំការមន | ១០២១៩២៤ | ១៩៩៤ | អាហារ៉ណ នីហារ៉ណ | ឈុន ប៊ុនថា |
| ៣៤ | ភោជនីយដ្ឋាន កុងទីណង់តាល់ | ផ.៦A ស/កជ្រោយចង្វា ខ.ឫស្សីកែវ | ១០២២០៣៤ | ១៩៩៦-១៩៩៧ ១៩៩៨ | ភោជ. | អៀម បូផារី |
| ៣៥ | អាយ ប៊ី អិន | ១៣០ ផ.១៣៦ ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០២២០៩០ | ១៩៩៦-១៩៩៧ ១៩៩៨ | អាហារ៉ណ នីហារ៉ណ | ពុធ សេរី |
| ៣៦ | មេស័ត អ៊ិនធើត្រេត ចំកាត់ | ៨២ ផ.មុនីរ៉េត ស/កបឹងសាឡាង ខ.ទួលគោក | ១០២២១៣៣ | ១៩៩៦ | អាហារ៉ណ នីហារ៉ណ | សុំ ចុងហ៊ាក់ |
| ៣៧ | អាថិច ត្រេឌីង និង អ៊ិនវិសមែន | ៧៨៣០ ផ.៩៣ ស/កបឹងត្របែក ខ.ចំការមន | ១០២២១៩៥ | ១៩៩៦ | អាហារ៉ណ នីហារ៉ណ | សេង ម៉េង |
| ៣៨ | ម៉េត្រូម៉ូទ័រ ខេមបូឌា | ២៣ ផ.១១៤កែង៦៧ ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០២២៦៣៩ | ១៩៩៦ ដល់ ២០០០ | អាហារ៉ណ នីហារ៉ណ | ឡាយ ជឹងហេង |
| ៣៩ | ភោជនីយដ្ឋាន ហ្វា ខាន់ | ១៦៥ ផ.មុនីវង្ស ស/កមនោរម្យ ខ.៧មករា | ១០០១០៨៨ | ១៩៩៦ | ភោជ. | លី យូឡាន |
| ៤០ | សណ្ឋាគារ ឆាយណាថោន | ៨៦ ផ.២១៤ ស/កបឹងរាំង ខ.ដូនពេញ | ១០០១០៩៥ | ១៩៩៦ | សណ្ឋាគារ | សុខ គីម |
| ៤១ | ថៃ មិត អាហារ៉ណ នីហារ៉ណ | ផ.សុធារស ស/កទន្លេបាសាក់ ខ.ចំការមន | ១០២២៦០៦ | ១៩៩៦ | អាហារ៉ណ នីហារ៉ណ | សច្ចៈភ័ណ្ឌ សុសលសាន់ |
| ៤២ | ភោជនីយដ្ឋាន ស្តេចនាគ | ១៦ ផ.៦A ស/កជ្រោយចង្វា ខ.ឫស្សីកែវ | ១០២២៩០៣ | ១៩៩៧-១៩៩៨ | ភោជ. | លុយ ងួន |
| ៤៣ | ហង្សា | ១១៥Eo ផ.ព្រះសីហនុ ស/កបឹងព្រលឹត ខ.៧មករា | ១០២៣០៦៨ | ១៩៩៧-១៩៩៨ | ពាណិជ្ជកម្ម | ហួយ ពៅ |
| ៤៤ | ខេមបូ ត្រេឌីង | ១២៧AEo ផ.២៤៥ ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០២៣២១១ | ១៩៩៨-១៩៩៩ ២០០០ | ពាណិជ្ជកម្ម | ឡោ ឡេង |
| ៤៥ | ជីផាម | ៧៦A ផ.សម្តេចប៉ាន ស/កបឹងរាំង ខ.ដូនពេញ | ១០២៣២៦៦ | ១៩៩៨-១៩៩៩ | | រ៉ាន់ មុនី |

| | | | | | | |
|---|---|---|---|---|---|---|
| ៤៦ | សានីម៉ិចកូ | ៤ ផ.៥៦៦ ស/កបឹងកក់១ ខ.ទួលគោក | ១០២៣៤១០ | ១៩៩៧ | | ហង់ ឆាម |
| ៤៧ | អេស្យា ខមម្ទូនីខេហ្សិន | ១៤៩E₀ ផ.១២៨ ស/កមិត្តភាព ខ.៧មករា | ១០២៤២១២ | ១៩៩៧-១៩៩៨ | អាហារ៉ណ នីហារ៉ណ | មាស ស៊ីណា |
| ៤៨ | ជៀមផែន អាហារ៉ណ នីហារ៉ណ | ២២៣ ផ.មុនីវង្ស ស/កអូរឬស្សី៤ ខ.៧មករា | ១០២៤៣៦៦ | ១៩៩៧ | អាហារ៉ណ នីហារ៉ណ | ជៀប ផែន |
| ៤៩ | ហ្វាន់ ហ្វេរ | ៤៥ ភូមិឬស្សី ស/កស្ទឹងមានជ័យ ខ.មានជ័យ | ១០២៤៥២០ | ១៩៩៧ | ឧស្សាហកម្ម | ឡាំ យ៉ាស៊ីង |
| ៥០ | ភូ ហាក់ ត្រេឌីង | ៩E₀ ផ.១១២ ស/កផ្សារដេប៉ូ៣ ខ.ទួលគោក | ២០២៥៣៨៩ | ១៩៩៩ | អាហារ៉ណ នីហារ៉ណ | ហេង ស៊ា |
| ៥១ | លាង អេងឈិន អាហារ៉ណ នីហារ៉ណ | ២១៩ CA ផ.ព្រះមុនីវង្ស ស/កអូរឬស្សី៤ ខ.៧មករា | ១០០០៤៣៩ | ១៩៩៤ | សេវា | លាង អេងឈិន |
| ៥២ | ឆាងអាន អន្តរជាតិ អាហារ៉ណ នីហារ៉ណ | ១៤៧ ផ.១៦៩ ស/កវាលវង់ ខ.៧មករា | ១០០០៦៧០ | ១៩៩៤ | ពាណិជ្ជកម្ម | ឡ ពន្ទក |
| ៥៣ | បាត់ធីប្អូយ ត្រេតដីរ | ២០០-២០២ ផ.កម្ពុជាក្រោម ស/កមិត្តភាព ខ.៧មករា | ១០០១១៩៨ | ១៩៩៤<br>១៩៩៥<br>១៩៩៦<br>១៩៩៧<br>១៩៩៨ | ពាណិជ្ជកម្ម | ជីវ គង់ហ៊ |
| ៥៤ | ធនាគារគណទានកម្ពុជា | ៧៤ ផ.ព្រះនរោត្តម ស/កជ័យជំនះ ខ.ដូនពេញ | ១០០១២៤២ | ១៩៩៨ | | ជុន ស៊ីវ៉េង |
| ៥៥ | ធាន យាង អាហារ៉ណ នីហារ៉ណ សំណង់ | ៩E₀ ផ.១១១ ស/កអូរឬស្សី១ ខ.៧មករា | ១០០១៤៥១ | ១៩៩៤ | | ស៊ុំ ឡេង |
| ៥៦ | អ៊ិនធ័រហ្គ្រីធី អេបជើរល | ១៦៥៣ ផ.២ ស/ក ចាក់អង្រែក្រោម ខ.មានជ័យ | ១០០១៥៣៩ | ១៩៩៤<br>១៩៩៥<br>១៩៩៦<br>១៩៩៧ | ឧស្សាហកម្ម កាត់ដេរ | លីម គឹមសុង |
| ៥៧ | សូស៊ីតេល ស៊ីដាប់ប៊ីលយូអ៊ី បណ្តាញប្រព័ន្ធវិទ្យុលេខ | ១០៧ ផ.ព្រះសីហនុ ស/កបឹងព្រលឹត ខ.៧មករា | ១០០១៦០៥ | ១៩៩៤ | | ចាង ជីនឈូង |
| ៥៨ | ក្លឹបបុកប៊ីយ៉ា និង វិដេអូហ្គេម | ២៦១E₀ ផ.១២៨ ស/កមិត្តភាព ខ.៧មករា | ១០០១៦៣៨ | ១៩៩៥ | | បូ ចាន់ធី |
| ៥៩ | ឆៀន ពរ អាហារ៉ណ នីហារ៉ណ | ១៧ ផ.៥០ ស/កវត្តភ្នំ ខ.ដូនពេញ | ១០០២២៥៤ | ១៩៩៦ | | យូហុង |
| ៦០ | ភ្នំពេញថ្មី ហ្គាមិន អិលធីឌី | ៤៤ ផ.១១១ ស/កបឹងព្រលឹត ខ.៧មករា | ១០០២៦៩៤ | ១៩៩៧ | | លាង ឃី |
| ៦១ | អាគារចរភូមិន្ទកម្ពុជា | ២៤ ផ.ក្រមួនស ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០០៣២០០ | ១៩៩៥<br>១៩៩៦ | សេវាកម្ម | អ៊ិត វិជិត/ខ្មែរ |
| ៦២ | ជនវ៉ែល ខេមបូដា អ៊ិនធើ ណាស្យូណាល់ ខប | ២៨៦ ផ.ទេពផន ស/កទឹកល្អក់៣ ខ.ទួលគោក | ១០០៤៥៧៥ | ១៩៩៩ | | យ៉ាង ស៊ុនចាង |
| ៦៣ | ខូរិកស៍ ខេមបូឌា ខូ អិលធីឌី | ១២៩ CE₀ ផ.ម៉ៅសេទុង ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០០៥៤៨៨ | ១៩៩៩ | ពាណិជ្ជកម្ម | ខូវ លឹមសុង |
| ៦៤ | ហេណារ (ខេមបូឌា) ហ្គាមិន អ៊ិនធើណាស្យូណាល់ | ផ.វេងស្រេង ស/កចោមចៅ ខ.ដង្កោ | ១០០៥៨១៨ | ១៩៩៩ | កាត់ដេរ | SIMA ZHONGZHI |
| ៦៥ | លឹម ឆេងកាង ខូអិលធីឌី | [illegible]៨ ផ.១៥៩ ស/កទួលស្វាយព្រៃ២ ខ.ចំការមន | ១០០៥៩៥០ | ២០០១ | ពាណិជ្ជកម្ម | ជុន សារឿន |
| ៦៦ | សណ្ឋាគារ សាំងហ្គាពូរ ២ | ២១ [illegible] ស/កផ្សារថ្មី៣ ខ.៧មករា | ១០០៥៩៧២ | ៩៧-៩៨-៩៩ | សេវាកម្ម | ជៀម អាំងខេន |

| | | | | | | |
|---|---|---|---|---|---|---|
| ៦៧ | ផាច់ គីមសាន អាហារីណ នីហារីណ | ១៤៨ E, ផ.២១៧ ស/កអូរឫស្សី៣ ខ.៧មករា | ១០០៦៩៩៩ | ២០០០ | ពាណិជ្ជកម្ម | ស ស៊ី |
| ៦៨ | ហេង ហួតលី | ៦២១ ផ.ព្រះមុនីវង្ស ស/កបឹងកេងកង៣ ខ.ចំការមន | ១០០៦៧៩៣ | ២០០១ | ពាណិជ្ជកម្ម | ម៉ែត សំបូរ |
| ៦៩ | ឈាវ ស្រ៊ុន អាហារីណ នីហារីណ | ៥៦៧ ស/កឫស្សីកែវ ខ.ឫស្សីកែវ | ១០០៦៩៦២ | ២០០០ | ពាណិជ្ជកម្ម | អៀវ ឫទ្ធិ |
| ៧០ | ម៉ាល់ឌី មេហ្គា អ៊ិមផត និង អ៊ិចផត ខេមផេនី | ២៧ ផ.៣០៦ ស/កបឹងកេងកង១ ខ.ចំការមន | ១០០៧៤៤៦ | ២០០០ | ពាណិជ្ជកម្ម | ហួ ពិសិទ្ធ |
| ៧១ | ហ្សី អីមកា តិចណូឡូហ្សី | ៦ ផ.ព្រះមុនីរ៉េត ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០០០០៩៨ | ១៩៩៦-<br>១៩៩៩<br>២០០០ | ពាណិជ្ជកម្ម | ខូវ ហ្សង់មីស្សែល |
| ៧២ | ខ្មែរ អេជេនស៊ី | ៥១ D ផ.ម៉ៅសេទុង ស/កបឹងកេងកង១ ខ.ចំការមន | ១០២០១៩៧ | ១៩៩៦ | ពាណិជ្ជកម្ម | វ៉ាន ដារិត |
| ៧៣ | រស្មីបូព៌ា អាហារីណ នីហារីណ ដឹកជញ្ជូន | ២៤០ $CE_0$ ផ.ទេពផន ស/កផ្សារដេប៉ូ១ ខ.ទួលគោក | ១០២០៧៣៦ | ១៩៩៥ | | ឃួន សុខន |
| ៧៤ | សណ្ឋាគារ តារារះ | ៤០-៤២ ផ.៣៦០ ស/កបឹងកេងកង៣ ខ.ចំការមន | ១០២៥៣៩៦ | ១៩៩៨ | សេវាកម្ម | សែម ស៊ុនដារ៉ា |
| ៧៥ | ខេង ឃាង អាហារ/ណ នីហារីណ | ៨៨ $E_0$ ផ.៦៧ ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០២៥៤៥៥ | ១៩៩៩ | ពាណិជ្ជកម្ម | ខេង ឃាង |
| ៧៦ | ជិន ឡុងហ្វុង គ្រេឌីង | ១៧២ $E_0$ ផ.១៣២ ស/កទឹកល្អក់១ ខ.ទួលគោក | ១០២៥៩២៨ | ១៩៩៩ | ពាណិជ្ជកម្ម | ទន់ ភាព |
| ៧៧ | ហេង ប៊ុនហាក់ | ១២៥ $E_0$ ផ.៣៥៨ ស/កទួលស្វាយព្រៃ ខ.ចំការមន | ១០២៦០០៥ | ១៩៩៩ | ពាណិជ្ជកម្ម | ម៉ិន យាង |
| ៧៨ | គៀត វាសនា | ៦៣ $E_0$ ផ.២៨៦ ស/កអូរឡាំពិក ខ.ចំការមន | ១០២៨០៥១ | ២០០១ | ពាណិជ្ជកម្ម | គៀត វាសនា |
| ៧៩ | ធី ដាប់ប៊ែលយូ | ១២៥ $E_0$ ផ.៣៥៨ ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០២៦២៦៩ | ១៩៩៩ | ពាណិជ្ជកម្ម | ស្រឿន សុធា |
| ៨០ | សណ្ឋាគារ ឡាប៉ៃយុត | ២៣៤ $E_0$ ផ.១៣០ ស/កផ្សារថ្មី៣ ខ.ដូនពេញ | ១០៤០០២១ | ១៩៩៨ | សេវាកម្ម | គ្រួចសេង |
| ៨១ | សណ្ឋាគារ ឡាក់ឃីអ៊ីន | ១១ ផ.២៥៤ ស/កចតុមុខ ខ.ដូនពេញ | ១០៤០០១០ | ១៩៩៤ | | កែវ សញ្ញមុំ |
| ៨២ | សណ្ឋាគារ អូរិនថល | ៣៥០ ផ.២១៧ ស/កអូរឫស្សី២ ខ.៧មករា | ១០៤០០៣២ | ១៩៩៤ | | គង់ ទ្រីវ |
| ៨៣ | សណ្ឋាគារ ដូឡាលីន | ១២ ផ.រុស្សី ស/កផ្សារដេប៉ូ ខ.ទួលគោក | ១០៤០៥៦០ | ១៩៩៤ | | មូល ហ៊ន |
| ៨៤ | ភ្នំពេញ ម៉ូធ័រ វើក | ១៤ $ABE_0$ ផ.១១១ ស/កអូរឫស្សី ខ.៧មករា | ១០៤០៧៨០ | ១៩៩៦<br>១៩៩៧<br>១៩៩៨ | ពាណិជ្ជកម្ម | ទី ពិសិដ្ឋ |
| ៨៥ | សំណង់ ម៉េងហេង | ៤១ $E_0$ ផ.១៧២ ស/កផ្សារថ្មី៣ ខ.ដូនពេញ | ១០៤០៨០២ | ១៩៩៦-<br>១៩៩៩ | សេវាកម្ម | សាន ម៉េងហេង |
| ៨៦ | ហ្គូលឌីន សី ស៊ីពភីង | ផ.៥ ស/កឫស្សីកែវ ខ.ឫស្សីកែវ | ១០៤០៩៥៦ | ១៩៩៤<br>១៩៩៥ | សេវាកម្ម | វង់ សំអាត |
| ៨៧ | នរ៉ា ពាណិជ្ជ សំណង់ | ៦០ ផ.១១៨ ស/កទឹកល្អក់១ ខ.ទួលគោក | ១០៤១០១១ | ១៩៩៥ | ពាណិជ្ជកម្ម | ច័ន្ទ នរ៉ា |
| ៨៨ | សំណង់ សិល្បការ្យ | ផ.រុស្សី ស/កទឹកថ្លា ខ.ឫស្សីកែវ | ១០៤១៣០៨ | ១៩៩៤ | | ហេ លឹមសេង |
| ៨៩ | វីឡា ប៉ាក | ១៥៩ $E_1$ ផ.១១០ ស/កវត្តភ្នំ ខ.ដូនពេញ | ១០៤១៤៣០ | ១៩៩៦ | | វ៉ា ច័ន្ទណា |
| ៩០ | ឌីវហៀន | ១៥ ផ.៧២៨កែង២៨៧ ស/កបឹងកក់ ខ.ទួលគោក | ១០៤១៧០៤ | ១៩៩៥ | | រ៉ូប៊ិត អ៊ុង |
| ៩១ | ខេមទ្រេន | ១៣ ផ.១៥៤ ស/កផ្សារកណ្ដាល១ ខ.ដូនពេញ | ១០៤១៩១៣ | ១៩៩៧<br>១៩៩៨ | ពាណិជ្ជកម្ម | អ៊ុក គីមហុង |

| | | | | | | |
|---|---|---|---|---|---|---|
| ៩២ | ខេមបូតិច អេចខេ | ១៦ E₀ ផ.៩ ស/កទន្លេបាសាក់ ខ.ចំការមន | ១០៤១៩៩០ | ១៩៩៥-<br>១៩៩៧<br>១៩៩៨<br>១៩៩៩ | | ឃីម យូ |
| ៩៣ | អ៊ុយ ងួនជូ | ៦១៦ ផ.កម្ពុជាក្រោម ស/កផ្សារដេប៉ូ១ ខ.ទួលគោក | ១០៤២១៤៤ | ១៩៩៧ | ពាណិជ្ជកម្ម | ម៉ី ជូ |
| ៩៤ | សាន្តីក អគ្គីសនី | ៨១ E₀ ផ.១២៦ ស/កផ្សារថ្មី ខ.ដូនពេញ | ១០៤២២០០ | ១៩៩៧ | | ង៉ូវ សាយណៃយ៍ |
| ៩៥ | ខេមបូឌា អ៊ែរផេក | ផ.រុស្ស៊ី ស/កកាកាប ខ.ដង្កោ | ១០៤២៤៥២ | ១៩៩៧<br>១៩៩៨ | សេវាកម្ម | ប៉ាទ្រីស ប៉ាស៊ីដ |
| ៩៦ | ហូវ៉ាហ្គេនធីង | ១៣២ ផ.មុនីវង្ស ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០៤២៨៩៩ | ១៩៩៩ | | ស៊ីមូន ធី |
| ៩៧ | តាន់ អេស វណ្ណថា | ៩៧ BE₀ ផ.៦៣ ស/កចតុមុខ ខ.ដូនពេញ | ១០៤៣២៧៧ | ១៩៩៦ | ពាណិជ្ជកម្ម | តាន សៀងវណ្ណថា |
| ៩៨ | ចាយឌីស ស្ពង្សឹង | ផ.២៥៨ ស/កបឹងកក់១ ខ.ទួលគោក | ១០៤៣៣១០ | ១៩៩៨ | កាត់ដេរ | ចេង ស៊ីងចាន់ |
| ៩៩ | ធីណាស់ ខេមបូឌា | ផ.៥ ស/កស្វាយប៉ាក ខ.ឫស្សីកែវ | ១០៤៣៣៧៦ | ១៩៩៦<br>១៩៩៧<br>១៩៩៨ | ឧស្សាហកម្ម | ប៊ុនយ៉ាមីន អាប់ឌុល រ៉ាហ៊ីម |
| ១០០ | ខេមបូឌា បេមប៊ូ | ៣៩ AE₀ ផ.២៨៧ ស/កទឹកល្អក់២ ខ.ទួលគោក | ១០៤៣៨៣៨ | ១៩៩៧ | | ញ៉ែម សុជាន់ណា |

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សង្ឃឹម និង ជឿជាក់ថា លោក-លោកស្រី ជាប្រធាន អភិបាល ឬ បណ្ណាធិការ ដែលទទួលខុសត្រូវក្រុមហ៊ុន ដូចមានឈ្មោះក្នុងបញ្ជីរាយនាមខាងលើ ពិតជារួសរាន់អញ្ជើញមកជួបដោះស្រាយ ទូទាត់បំណុលពន្ធអោយបានចប់សព្វគ្រប់តាមការកំណត់ជាមិនខានឡើយ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ : ៦២៣ សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០២

# សេចក្តីជូនដំណឹង

**ចំពោះ**

**ក្រុមហ៊ុនជំពាក់បំណុលពន្ធហើយបាត់ខ្លួនរកមិនឃើញ**

**បន្តពីសេចក្តីជូនដំណឹងលេខ ០២៥ សហវ.ពដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០២**

កន្លងមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញនូវសេចក្តីជូនដំណឹងលេខ ០២២ សហវ.ពដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ ដោយបានផ្សព្វផ្សាយតាមបណ្តាញសារពត៌មាន ដើម្បីធ្វើការរំលឹកជាចុងក្រោយបង្អស់ ដល់លោក-លោកស្រី ជាប្រធានក្រុមហ៊ុនទាំងអស់ ដែលនៅជំពាក់បំណុលពន្ធរដ្ឋ សូមអញ្ជើញមកធ្វើការទូទាត់សងបំណុលពន្ធអោយបានចប់សព្វគ្រប់មុនថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០២ ជាកំហិត ។ មានក្រុមហ៊ុនមួយចំនួន បានបំពេញកាតព្វកិច្ចទូទាត់បំណុលពន្ធរួចហើយ ។ ប៉ុន្តែរហូតដល់ពេលនេះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសង្កេតឃើញថា មានក្រុមហ៊ុនមួយចំនួនដែលនៅជំពាក់បំណុលពន្ធរដ្ឋ ហើយបាត់ខ្លួនដោយបិទក្រុមហ៊ុនហើយបង្កើតក្រុមហ៊ុនថ្មី និង ក្រុមហ៊ុនមួយចំនួនទៀត បានផ្លាស់ប្តូរអាស័យដ្ឋានច្រើនលើកច្រើនសារ ដោយមិនផ្តល់ពត៌មានដល់រដ្ឋបាលពន្ធដារ ហើយក្រុមហ៊ុនទាំងនោះនៅតែរឹងរូសមិនព្រមបំពេញកាតព្វកិច្ច ហើយមិនបានអញ្ជើញមកទំនាក់ទំនងធ្វើការដោះស្រាយទូទាត់បំណុលពន្ធ តាមសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខាងលើឡើយ ។

ជាថ្មីម្តងទៀតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងជាចុងក្រោយបង្អស់ដល់លោក-លោកស្រី ដែលជាប្រធាន អភិបាល ឬ បណ្ណាធិការដែលទទួលខុសត្រូវក្រុមហ៊ុន ដូចមានរាយនាមខាងក្រោមនេះ បន្តពី ១០០ក្រុមហ៊ុន ដែលមានក្នុងសេចក្តីជូនដំណឹងលេខ ០២៥ សហវ.ពដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០២ ដែលបានចុះផ្សាយរួចហើយក្នុងសារពត៌មានរស្មីកម្ពុជា លេខ ២៨៨៧ ចុះថ្ងៃ១៨ ខែតុលា ឆ្នាំ២០០២ និងក្នុងសារពត៌មានកោះសន្តិភាព លេខ ៤៦៤៣ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០២ អញ្ជើញមកដោះស្រាយបំណុលពន្ធនៅនាយកដ្ឋានពន្ធដារ មិនអោយហួសពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០២ ។ ករណីលោក-លោកស្រី មិនបានអញ្ជើញមកធ្វើការដោះស្រាយទូទាត់បំណុលពន្ធតាមការកំណត់ខាងលើនេះទេ លោក-លោកស្រី នឹងត្រូវប្រឈមមុខនឹងការតឹងទារ និងបណ្តឹងចោទប្រកាន់តាមផ្លូវច្បាប់ជាធរមាន ។

| ល.រ | នាមករណ៍សហគ្រាស | អាស័យដ្ឋានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ | លេខអត្តសញ្ញាណកម្ម (TIN) | ការិយបរិច្ឆេទជំពាក់ពន្ធ | មុខរបរ | ឈ្មោះអ្នកគ្រប់គ្រង |
|---|---|---|---|---|---|---|
| ១០១ | សាន់ហ្វា អិនធ័រណេស្យូណល់គ្រេឌ | ៩៥៣ ផ.១១៨ ស/កផ្សារថ្មី ខ.ដូនពេញ | ១០០០៩១២ | ១៩៩៦ | | ចៅ គន្ធណារី |
| ១០២ | សុខ លាង អាហារ័ណ ទីហារ័ណ | ២៦ E៣ ផ.៣១០ ស/កទូលស្វាយព្រៃ ខ.ចំការមន | ១០០០៩៥៦ | ១៩៩៤ | | សុខ លាង |
| ១០៣ | ពិភពពាណិជ្ជ | ៣៣ ផ.២០៨ ស/កបឹងរាំង ខ.ដូនពេញ | ១០០១១៥៤ | ១៩៩៤<br>១៩៩៥<br>១៩៩៦ | សេវាកម្ម | ឡាយ គីមសុង |
| ១០៤ | ទ្រីសែលុយឡា គមនាគមន៍កម្ពុជា | ៣៣ E៣ ផ.៣១៥ ស/កបឹងកេងកង១ ខ.ចំការមន | ១០០១៦២៧ | ១៩៩៥ | សេវាកម្ម | យូសុះ រូស្តី |
| ១០៥ | ដុងកាមធីមបើរ កូអែលធីឌី | ៧៣ ផ.ឧកញ៉ាទូកែវ ស/កទន្លេបាសាក់ ខ.ចំការមន | ១០០១៩២៤ | ១៩៩៦ | | ស៊ុង អ៊ុងហូ |
| ១០៦ | ដាយមិនដ៏ ឧបភោគបរិភោគ | ១១៩ E៣ ផ.១០៧ ស/កអូរឫស្សី ខ.៧មករា | ១០០១៩៥៧ | ១៩៩៥ | ពាណិជ្ជកម្ម | លី សារ៉េត |
| ១០៧ | សេរីធន អាហារ័ណ ទីហារ័ណ | ៧៨ E៣ ផ.២១៧ ស/កទូលស្វាយព្រៃ២ ខ.ចំការមន | ១០០២៣៥៣ | ១៩៩៤<br>១៩៩៥<br>១៩៩៦ | | យិន ម៉េង |
| ១០៨ | អ៊ិនធីប៊ុក ខ្ទីម ខូអិលធីឌី | ២៦៩ ផ.៥ ស/កគីឡូម៉ែត្រលេខ៦ ខ.ឫស្សីកែវ | ១០០២៩៦៩ | ១៩៩៦ | ពាណិជ្ជកម្ម | លី ហុង |
| ១០៩ | សាំបូ គ្រឿង | ៤០០ ផ.មុនីវង្ស ស/កបឹងកេងកង ខ.ចំការមន | ១០០៣១០១ | ១៩៩៧ | | ខ្វាង វុនជាត |
| ១១០ | សៀង អ៊ី | ៣៨៥ E ផ.១២៨ ស/កមិត្តភាព ខ.៧មករា | ១០០៣១១២ | ១៩៩៤-<br>១៩៩៦<br>១៩៩៧ | | សៀង អ៊ី |
| ១១១ | គូ ឈិន អ៊ិនវែស្តមិន ខូអិលធីឌី | ៣៤-៣៨ ផ.២៨៨ ស/កបឹងកេងកង១ ខ.ចំការមន | ១០០៣៤០៩ | ១៩៩៨ | សេវាកម្ម | អ៊ន ហ៊ុយ |
| ១១២ | វិតាកូ ភីធីអ៊ី អែលធីឌី | ៨៣២ E៣ ផ.កម្ពុជាក្រោម ស/កទឹកល្អក់១ ខ.ទួលគោក | ១០០៣៨១៦ | ១៩៩៧ | ពាណិជ្ជកម្ម | វីអូ ហ្វ្រង់ស៊ីស |
| ១១៣ | សាម ហាក់ហេង | ១១ ផ.២៨៦ ស/កអូឡាំពិក ខ.ចំការមន | ១០០៣៨២៧ | ១៩៩៧<br>១៩៩៨ | | ជា ជុន |
| ១១៤ | ភោជនីយដ្ឋាន ឡារ៉ូតុង | ៣៧៩ ផ.ព្រះស៊ីសុវត្ថិ ស/កជ័យជំនះ ខ.ដូនពេញ | ១០០៤៦០៨ | ១៩៩៧ | សេវាកម្ម | ប៊ុយ ហ្វាអ៊ីវ |
| ១១៥ | សែន ចំរើន | ៩០ E₂ ផ.៥៣ ស/កផ្សារថ្មី៣ ខ.ដូនពេញ | ១០០៦៤៨៩ | ១៩៩៩ | ពាណិជកម្ម | ឈុន ស៊ុយ |
| ១១៦ | ភី យ៉ាត អិលធីឌី | ១៦២ ផ.២៦៥ ស/កទឹកល្អក់៣ ខ.ទួលគោក | ១០០៨១៨៣ | ២០០០ | សេវាកម្ម | PARK HAE YOUNG |
| ១១៧ | ស្រ៊ុន ស្រ៊ុន | ៣៩ E៣ ផ.១៣៤ ស/កមិត្តភាព ខ.៧មករា | ១០២០១៤២ | ១៩៩៩ | ពាណិជ្ជកម្ម | បាន ហួត |
| ១១៨ | ស៊ីនដាយ អាហារ័ណ ទីហារ័ណ | ៦៣ ផ.ព្រះនរោត្តម ស/កផ្សារថ្មី៣ ខ.ដូនពេញ | ១០២០៦៩២ | ១៩៩៤ | | [illegible]សុន |
| ១១៩ | លឹម លីម៉ិច អាហារ័ណ ទីហារ័ណ | ២៤៦ B ផ.ព្រះមុនីវង្ស ស/កបឹងរាំង ខ.ដូនពេញ | ១០២០៧៩១ | ១៩៩៤ | ពាណិជ្ជកម្ម | លឹម [illegible] |
| ១២០ | ហេភា ពាណិជ្ជ ដឹកជញ្ជូនផ្លូវទឹក | ២៧៨ E៣ ផ.កម្ពុជាក្រោម ស/កមិត្តភាព ខ.៧មករា | ១០២១៤២៩ | ១៩៩៥ | សេវាកម្ម | [illegible] |

| | | | | | | |
|---|---|---|---|---|---|---|
| ១២១ | ហ្វែរទោសន៍ ហ្វាម៉ា ខេមបូឌា | ៩៧ E, ផ.៩៣ ស/កវត្តភ្នំ ខ.ដូនពេញ | ១០២២២៥៤ | ១៩៩៦<br>១៩៩៧<br>១៩៩៨<br>១៩៩៩ | ពាណិជ្ជកម្ម | ទាង ឆាយយ៉ាណា |
| ១២២ | ជ្វីអេសជី ហ្គោលដែន ស្តេលត្រង់ស្ព័រថ៍ | ១៣ ផ.១៤២ ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០២២៣៤២ | ១៩៩៦ | សេវាកម្ម | ជា លីប |
| ១២៣ | ស៊ុន ហ្វុងហុង | ១២១ E, ផ.១៤៥ ស/កផ្សារកណ្តាល២ ខ.ដូនពេញ | ១០២២៤៨៥ | ១៩៩៩ | ពាណិជ្ជកម្ម | លី សុជា |
| ១២៤ | សង្កែ សណ្ឋាគារ | ៥ ផ.២១៧ ស/កវាលវង់ ខ.៧មករា | ១០២២៧៨២ | ១៩៩៧<br>១៩៩៨ | សេវាកម្ម | ចាំង ស្យេក |
| ១២៥ | ខ្មែរអាំងដូឆាយណាហ្វូដ | ១៤២-១៤៤ ផ.កម្ពុជាក្រោម ខ.មនោរម្យ ខ.៧មករា | ១០២៣៧៤០ | ១៩៩៩ | ពាណិជ្ជកម្ម | ជីវ សុខអ៊ូ |
| ១២៦ | សូឡា បីនទីហ្វិច | ២៤៦ ផ.ព្រះមុនីវង្ស ស/កបឹងរាំង ខ.ដូនពេញ | ១០២៣៨៥០ | ១៩៩៧ | | លឹម ណារី |
| ១២៧ | ស៊ីងហ្គាពួរ ផេភើប្រូដាក់ | ៦៤០ ផ.២ ស/កចាក់អង្រែក្រោម ខ.មានជ័យ | ១០២៦៩១១ | ២០០១ | ឧស្សាហកម្ម | ឡុច សារ៉េត |
| ១២៨ | សណ្ឋាគារ ប៉ៃលិន | ២៩៩ B ផ.ព្រះមុនីវង្ស ស/កអូរឬស្សី៤ ខ.៧មករា | ១០៤០២៣០ | ១៩៩៧<br>១៩៩៨ | សេវាកម្ម | លាង អេងឈិន |
| ១២៩ | លី ហេងជុន អាហារ៍ណ ទីហារ៍ណ | ៦៩ ផ.១១៨ ស/កផ្សារថ្មី១ ខ.ដូនពេញ | ១០៤០៦៩២ | ១៩៩៤ | | ប៊ុន លី |
| ១៣០ | ហ៊ួរ យូសេង អាហារ៍ណ ទីហារ៍ណ | ១៧៣ E, ផ.កម្ពុជាក្រោម ស/កមិត្តភាព ខ.៧មករា | ១០៤០៩១២ | ១៩៩៥<br>១៩៩៦ | ពាណិជ្ជកម្ម | តាំង ហុងឆាយ |
| ១៣១ | គណ្ឌចិន ណាយក្លិប | ០១ ផ.៨៤ ស/កទំនប់ទឹក ខ.ចំការមន | ១០៤១៣១៩ | ១៩៩៥ | សេវាកម្ម | ម៉ត់ ចាន់សុខន |
| ១៣២ | តាហ្វា អាហារ៍ណ ទីហារ៍ណ និង ដឹកជញ្ជូនផ្លូវគោក | ២០០ DE, ផ.១១៤ ស/កផ្សារថ្មី១ ខ.ដូនពេញ | ១០៤១៩០២ | ១៩៩៦<br>១៩៩៧<br>១៩៩៨ | ពាណិជ្ជកម្ម | ថៃ ទីណូ |
| ១៣៣ | អ៊ី អ៊ុម ជ្វី អ៊ែងជីរីងផារហ្វេង ខេអប្ផូខា | ៩ ផ.ព្រះសីហនុ ស/កចតុមុខ ខ.ដូនពេញ | ១០៤៣២៦៦ | ១៩៩៧<br>១៩៩៨ | សេវាកម្ម | តាន់ ហួហេរុ |
| ១៣៤ | អ៊ីមអិនស៊ី អ៊ិនខូរីស ខេមបូឌា ភីធីអ៊ី អែលធីឌី | ៥ ផ.៨១ ស/កបឹងរាំង ខ.ដូនពេញ | ១០៤៣៨៦០ | ១៩៩៧<br>១៩៩៨ | សេវាកម្ម | អិនជី ម៉េងចេង |
| ១៣៥ | សំណង់ យូញៀន | ១១១ ផ.១៤១ ស/កវាលវង់ ខ.៧មករា | ១០៤៤១២៤ | ២០០០<br>២០០១ | សេវាកម្ម | កេខ ច័ន្ទតារា |
| ១៣៦ | ស៊ូហ៊្វិត អាហារ៍ណ ទីហារ៍ណ | ៣១១ ផ.៦០៤ | ១០៤៤១៦៨ | ១៩៩៩ | | សេទ ស៊ុង |
| ១៣៧ | ស៊ុន ហ៊ុន គ្រឿង | ៤២៥ ផ.១២៨ ផ្សារដេប៉ូ១ ខ.ទួលគោក | ១០៤៤២២៣ | ១៩៩៨<br>១៩៩៩ | ពាណិជ្ជកម្ម | ប៊ុន ឈឿន |
| ១៣៨ | សំណង់ស៊ីវិល ស៊ីវិច កូអិលធីឌី | ១២ E, ផ.២១៣ ស/កវាលវង់ ខ.៧មករា | ១០៤៤៣៧៧ | ១៩៩៩<br>២០០០ | សំណង់ | ថម សាម៉េត |
| ១៣៩ | ជីប ហាប់ អ៊ីមប៉ិច | ១១១ ផ.ព្រះសីហនុ ស/កបឹងព្រលិត ខ.៧មករា | ១០៤៤៤៨៧ | ២០០០ | ពាណិជ្ជកម្ម | វិញ ហងឡុង |
| ១៤០ | កែម មាស អាហារ៍ណ ទីហារ៍ណ | ៥ E, ផ.២២៩ ស/កផ្សារដេប៉ូ១ ខ.ទួលគោក | ១០៤៤៨២៨ | ១៩៩៩ | ពាណិជ្ជកម្ម | សៅ មាឈី |
| ១៤១ | ជាន អ៊ីម៉ិច | ៥៥ E, ផ.៦៣ ស/កបឹងរាំង ខ.ដូនពេញ | ១០៤៥៦៨៦ | ១៩៩៦ | [illegible] | [illegible] |
| ១៤២ | ឈាវិយូ គេស្សស៊ីល | ១៥-១៦ ផ.១៦៤ ស/កអូរឬស្សី៣ ខ.៧មករា | ១០៤៥៧១៩ | ១៩៩៨-១៩៩៩<br>២០០០-២០០១ | ឧស្សាហ[illegible] | [illegible] |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤៣ | ថៃវ៉ា អ៊ិនដាសស្ទ្រី | ១៧៨២ ផ.៥ ស/កទួលសង្កែ ខ.ឬស្សីកែវ | ១០៤៥៧៤១ | ១៩៩៧ | ឧស្សាហកម្ម | វ៉ាង យីហើរ |
| ១៤៤ | ជាយីវ ខេមបូឌា អ៊ិនធីលៅស្យូណល ត្រេឌីង | ២៣៥ E, ផ.១៨២កែង២៥ ស/កទឹកល្អក់២ ខ.ទួលគោក | ១០៤៥៩៨៣ | ២០០១ | ពាណិជ្ជកម្ម | ស៊ូ ធិន |
| ១៤៥ | ជារ៉ូ អាហ័រលា ទីហ័រលា | ២១៥ E, ផ.៣១៧ ស/កបឹងកក់១ ខ.ទួលគោក | ១០៤៥៩៩៤ | ១៩៩៩ | ពាណិជ្ជកម្ម | សុខ សេង |
| ១៤៦ | សូយ ទ្រី | ៥៤ ផ.១១២ ស/កផ្សារដេប៉ូ៣ ខ.ទួលគោក | ១០៤៦២៥៨ | ១៩៩៩ | ពាណិជ្ជកម្ម | តែ សូយទ្រី |
| ១៤៧ | ហុង ស៊ីវ | ៤៦២ E, ផ.ព្រះមុនីវង្ស ស/កទន្លេបាសាក់ ខ.ចំការមន | ១០៤៦៤៤៥ | ២០០០ | ពាណិជ្ជកម្ម | តាំង ខេងស៊ុម |
| ១៤៨ | ខេមជេប អាហ័រលា ទីហ័រលា | ៨៨ E, ផ.៦៧ ស/កផ្សារកណ្ដាល២ ខ.ដូនពេញ | ១០៤៦៩២៩ | ១៩៩៩ | ពាណិជ្ជកម្ម | |
| ១៤៩ | អានឡុង អាហ្សេត អភិវឌ្ឍន៍ ពាណិជ្ជកម្ម អាហ័រលា ទីហ័រលា | ៨២ E, ផ.៦៧ ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០៤៧១២៧ | ១៩៩៩ ២០០០ ២០០១ | ពាណិជ្ជកម្ម | គូ តឹមឡុង |
| ១៥០ | អេស ប៊ី | ៤០០ ផ.ព្រះមុនីវង្ស ស/កបឹងកេងកង១ ខ.ចំការមន | ១០៤៧៦០០ | ២០០០ | ពាណិជ្ជកម្ម | VAN WENHONG |
| ១៥១ | ស៊ីអាយអិល ខេមបូឌា អាហ័រលា ទីហ័រលា | ១៣៥ ផ.ព្រះមុនីវ៉េត ស/កបឹងសាឡាង ខ.ទួលគោក | ១០៤៧៦៧៧ | ២០០០ | ពាណិជ្ជកម្ម | ប៊ុន មណីមាលា |
| ១៥២ | វិដេអូហ្គេម ក្លឹបទន្លេ មណ្ឌលកំសាន្ដ | ៧៥ ផ.១២៦ | ១០៦០១១០ | ១៩៩៥ | មណ្ឌល កំសាន្ដ | តាំង ឡុង |
| ១៥៣ | ការហ្វេ បកភា | ៣០៧ ៤, ផ.ព្រះបុធីវង្ស ស/កវរូរឬស្សី២ ខ.៧មករា | ១០៦០១៥៣ | ១៩៩៤ | ពាណិជ្ជកម្ម | កែវ ចាន់ធី |
| ១៥៤ | សណ្ឋាគារ ស៊ុន រ៉ា | ៤៨ ផ.ព្រះសីហនុ ស/កទន្លេបាសាក់ ខ.ចំការមន | [illegible]០៦០២៣០ | ១៩៩៤ | សណ្ឋាគារ | ប៊ូ ម៉េង |
| ១៥៥ | គង់ទ្រីវ អាហ័រលា ទីហ័រលា | ៨១៤ ផ.១២៨ ស/កទឹកល្អក់៣ ខ.ទួលគោក | ១០៦០៥០៥ | ១៩៩៥-១៩៩៨ | សេវាកម្ម | សៀង ផាវស៊ាង |
| ១៥៦ | ខេមបូឌា ឆាទ័រ | ១៤ E, ផ.១៣៦ ស/កផ្សារថ្មី៣ ខ.ដូនពេញ | ១០៦០៧០៣ | ១៩៩៤ | ពាណិជ្ជកម្ម | មាស ណារិទ្ធ |
| ១៥៧ | សាម ស៊ីន អាហ័រលា ទីហ័រលា | ៤ CE, ផ.១៦២ ស/កផ្សារដេប៉ូ១ ខ.ទួលគោក | ១០៦០៨៨០ | ១៩៩៤ | ពាណិជ្ជកម្ម | លួង ហ៊ីម |
| ១៥៨ | ខេមបូឌាន អេចប្រេស | ១៣៩ E, ផ.ព្រះស៊ីសុវត្ថិ ស/កវត្តភ្នំ ខ.ដូនពេញ | ១០៦១០៩៩ | ១៩៩៤ | ពាណិជ្ជកម្ម | ជា សារ៉េត |
| ១៥៩ | ស៊ីញ ដាយ អាហ័រលា ទីហ័រលា | ៥ E, ផ.២១៥ ស/កផ្សារដេប៉ូ ខ.ទួលគោក | ១០៦១២៤២ | ១៩៩៦ | ពាណិជ្ជកម្ម | លីន លន់ |
| ១៦០ | ឡុង ម៉េង អាហ័រលា ទីហ័រលា | ៦៧ E, ផ.១៣០ ស/កផ្សារចាស់ ខ.ដូនពេញ | ១០៦១២៥៣ | ១៩៩៥ | ពាណិជ្ជកម្ម | ឡុង ម៉េង |
| ១៦១ | ស៊ុបព្រែម ម៉ូច័រ អេជិនស៊ី ខេមបូឌា | ៤៦-៥០ ផ.១៣៩ ស/កវាលវង់ ខ.៧មករា | ១០៦១២៩៧ | ១៩៩៧ | | ឡាប តាបដាវីតាន |
| ១៦២ | សំណង់ ប៉ៃលិន | ២០ E, ផ.២១៧ ស/កវាលវង់ ខ.៧មករា | ១០៦១៣៤១ | ១៩៩៨ | សំណង់ | ហិន ចាន់ |
| ១៦៣ | រង្គសាលវិមានផ្កាយមាស | ០១ ផ.៥ ស/កទួលសង្កែ ខ.ឬស្សីកែវ | ១០៦១៤០៧ | ១៩៩៥-១៩៩៨ | រង្គសាល | សូ តឹមយ៉ាន |
| ១៦៤ | អូប៉ាសគង់ | ផ.ដូនពេញ ស/កវត្តភ្នំ ខ.ដូនពេញ | ១០៦១៤១៨ | ១៩៩៥-១៩៩៨ ១៩៩៩ | សេវាកម្ម | ជាវី លូស្ដ |
| ១៦៥ | ផ្សារសាន់តាន់ | ៤៧៧ E, ផ.ព្រះមុនីវង្ស | ១០៦១៤៤០ | ១៩៩៤ | ពាណិជ្ជកម្ម | [illegible] |
| ១៦៦ | អាយ ប៊ី អ៊ីម | ៥១ C ផ.២១៤ ស/កបឹងរាំង ខ.ដូនពេញ | ១០៦១៩០២ | ១៩៩៥ | ពាណិជ្ជកម្ម | [illegible] |
| ១៦៧ | តាំង លីសេង ហ្វាម៉ា | ៨ ផ.១៦៣ ស/កវាលវង់ ខ.៧មករា | ១០៦១៩២៤ | ១៩៩៥ | ពាណិជ្ជកម្ម | ហៀង សុឃុន |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦៨ | ខេមបូឌា ហូរយូ | ១៥ E₀ ផ.២៧៨ ស/កបឹងកេងកង១ ខ.ចំការមន | ១០៦២០១២ | ១៩៩៥ | | ឡៅ សាន |
| ១៦៩ | ជា ចំណាន ហ្វាមើស្សូទីខល | ២០ E₀ ផ.២៩៨ ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០៦២០៨៩ | ១៩៩៧<br>១៩៩៨ | ពាណិជ្ជកម្ម | ជា ចំណាន |
| ១៧០ | កម្ពុជាឧស្ម័ន និង ប្រេងឥន្ធនៈ | ១៤៣ ផ.១៩ ស/កព្រែកព្នៅ ពញាញ កណ្ដាល | ១០៦២២៨៧ | ១៩៩៦<br>១៩៩៧<br>១៩៩៨ | ឧស្សាហកម្ម | លី ម៉េង |
| ១៧១ | ស្វាយ រៀង អេគ្រីខាលធ័រ ឌីវ៉ឡុបមែន | ១៥ E₀ ផ.៥២៨កែង២៨៧ ស/កបឹងកក់ ខ.ទួលគោក | ១០៦២៩៧០ | ១៩៩៧ | | ស៊ុ សុជុន |
| ១៧២ | ស៊ីវ លាង អ៊ិនធ័រប្រាយស៍ | ១១៣ ផ.១៣៤ ស/កផ្សារកណ្ដាល ខ.ដូនពេញ | ១០៦៣០៦៨ | ១៩៩៧ | | ហ៊ុយ ស៊ីលាង |
| ១៧៣ | វេងសែ អាហ័រណេ នីហ័រណេ | ២៨៦ DE₀ ផ.ព្រះមុនីវង្ស ស/កបឹងរាំង ខ.ដូនពេញ | ១០៦៣៨១៦ | ១៩៩៩ | ពាណិជ្ជកម្ម | សែន សំណាង |
| ១៧៤ | ហុង លី ត្រេតឌីត និង អ៊ិនធើប្រាយស៍ | ១៧ E ផ.ព្រះសីហនុ ស/កបឹងកេងកង២ ខ.ចំការមន | ១០៦៤៤៦៥ | ១៩៩៨-២០០០ | សេវាកម្ម | ស៊ុ យាងហួរ |
| ១៧៥ | មែន ឡាញ អាហ័រណេ នីហ័រណេ | ១០៣ ផ.១០៤ ស/កវត្តភ្នំ ខ.ដូនពេញ | ១០៦៤៨២ | ១៩៩៩ | ពាណិជ្ជកម្ម | ឡ យាង |
| ១៧៦ | សាន់ ជាង អ៊ិនដាស្ទ្រីល ខូអិលធីឌី | ៦៩៧ ផ.១២៨ ស/កទឹកល្អក់១ ខ.ទួលគោក | ១០៦៥៤៦៦ | ១៩៩៩ | ឧស្សាហកម្ម | ចិនា ហ៊ូម៉ឹង |
| ១៧៧ | ហ្វ្រាណាស៊ី | ១៨ E₀ ផ.៦៣ ស/កផ្សារថ្មី១ ខ.ដូនពេញ | ១០៦៥៥៧៦ | ១៩៩៨ | ពាណិជ្ជកម្ម | ស៊ិន ឃឹម |
| ១៧៨ | ខេមបូឌា អ៊ីមប្រូជីវ អិលធីឌី | ផ្លូវភូមិក្បាលដំរី ស/កកាកាប ខ.ដង្កោ | ១០៦៥៦០៩ | ១៩៩៧<br>១៩៩៨<br>១៩៩៩ | ឧស្សាហកម្ម | ហួង ចេងវ៉ៃ |
| ១៧៩ | ប៊ុណ្ណារី អាហ័រណេ នីហ័រណេ | ១៤៣ E₀ ផ.សហព័ន្ធរុស្ស៊ី ស/កកាកាប ខ.ដង្កោ | ១០៦៦៦១០ | ១៩៩៩ | ពាណិជ្ជកម្ម | ម៉ក ប៊ុណ្ណារី |
| ១៨០ | រ៉ា លទ់សែ ពាណិជ្ជកម្ម និង ដឹកជញ្ជូន | ៣៥ ផ.៣៦០ ស/កបឹងកេងកង១ ខ.ចំការមន | ១០៨០២៤១ | ១៩៩៥ | ពាណិជ្ជកម្ម | ញឹក ប៊ុនហុង |
| ១៨១ | កាត់ដេរ វិញ ហួរ | ១២២ S ផ.២ ស/កចាក់អង្រែលើ ខ.មានជ័យ | ១០៨១៨៧០ | ១៩៩៥<br>១៩៩៦<br>១៩៩៧<br>១៩៩៨ | ឧស្សាហកម្ម | វិញ ហួរ |
| ១៨២ | ជេ អ៊ី អេស អ័រ ចូដាកស៍ អាហ័រណេ នីហ័រណេ | ១៧៩ E₀ ផ.កម្ពុជាក្រោម ស/កមិត្តភាព ខ.៧មករា | ១០៨០០៤៣ | ១៩៩៤ | ពាណិជ្ជកម្ម | ឈិត ដារា |
| ១៨៣ | សណ្ឋាគារ ស៊ីតទី សង់ក្រាល់ | ១២៨ ផ.ព្រះមុនីវង្ស ស/កផ្សារថ្មី២ ខ.ដូនពេញ | ១០៨០៥៦០ | ១៩៩៤<br>១៩៩៥<br>១៩៩៦<br>១៩៩៧<br>១៩៩៩<br>២០០០ | សេវាកម្ម | Supachai Pooleiam |
| ១៨៤ | សណ្ឋាគារ រ៉ាម៉ាអ៊ិន | ៨ ផ.២៨២ ស/កទន្លេបាសាក់ ខ.ចំការមន | ១០៨០៥៩៣ | ១៩៩៤<br>១៩៩៥<br>១៩៩៧<br>១៩៩៨ | សេវាកម្ម | |
| ១៨៥ | នីហ័រណេ អាហ័រណេ កោះស៊ូ | ២៨៩ ផ.៥ ខ.ឫស្សីកែវ | ១០៨១៥២៨ | ១៩៩៦-១៩៩៩ | ពាណិជ្ជកម្ម | សេ សុខា |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨៦ | សណ្ឋាគារ ឆាយណាថោនថ្មី | ៤៩ ផ.២១៤ ស/កបឹងរាំង ខ.ដូនពេញ | ១០៨១២៦៤ | ១៩៩៥ | សេវាកម្ម | ចេង ស៊ូរ៉ុង |
| ១៨៧ | អ៊ិនដាសស្រ្ទី ហ្វុលដេយ | ផ.៦ A មុខកំពូល កណ្តាល | ១០៨១៨៣៦ | ១៩៩៥<br>១៩៩៦<br>១៩៩៧<br>១៩៩៨ | ឧស្សាហកម្ម | ឆាយ ភិនសាន |
| ១៨៨ | កម្ពុជាកាត់ដេរ លីមីធីត | ផ.៤ ស/កទឹកថ្លា ខ.ឫស្សីកែវ | ១០៨១៨៤៧ | ១៩៩៤<br>១៩៩៥<br>១៩៩៦<br>១៩៩៧<br>១៩៩៨<br>១៩៩៩ | ឧស្សាហកម្ម | ជា វៀឡុង |
| ១៨៩ | ណារីតា អាហារ័ណ ទីហារ័ណ | ១១០ ផ.ម៉ៅសេទុង ស/កទួលទំពូង១ ខ.ចំការមន | ១០៨២៤៧៤ | ១៩៩៦ | ពាណិជ្ជកម្ម | ឡុង ណារិទ្ធ |
| ១៩០ | ក្វាងលី ក្លូស៊ីង ម៉ាញ៉ូហ្វាក់ធើរីង អាំងឌ័ស្ត្រី | ផ.៥២៨ ស/កបឹងកក់១ ខ.ទួលគោក | ១០៨៤១៧៩ | ១៩៩៨ | ឧស្សាហកម្ម | ជូ ស៊ានសាយ |
| ១៩១ | ម៉ូតូខា អូតូជាតកូ អិលធីឌី | ២០៥ ផ.១៨២ ផ្សារដេប៉ូ១ ខ.ទួលគោក | ១០៨៤២០១ | ១៩៩៩ | ពាណិជ្ជកម្ម | សៀង សុខា |
| ១៩២ | អ៊ីម.ជេ.ធី.អេស អាប់ភែរ៉ែល | ផ.វែងស្រេង ខ.ដង្កោ | ១០៨៤៧៨៤ | ១៩៩៨ | ឧស្សាហកម្ម | លឹម សុភី |
| ១៩៣ | ញ៉ឹក វីរ៉ាត់ពាណិជ្ជ | ១៨ ផ.៥៩២ ស/កបឹងកក់២ ខ.ទួលគោក | ១០៨២៣៩៧ | ១៩៩៩ | ពាណិជ្ជកម្ម | ញ៉ឹក វីរ៉ាត់ |
| ១៩៤ | ន័រមែន អ៊ិនវេស្តមែន | ១២៥ ផ.២៥៣ ស/កទឹកល្អក់១ ខ.ទួលគោក | ១០៨៥១៣៦ | ១៩៩៧<br>១៩៩៨ | ឧស្សាហកម្ម | លី ហៀង |
| ១៩៥ | ឡាក់ព្រូវិណ្ណទី អាហារ័ណ ទីហារ័ណ និង សំណង់ | ២៩១ ផ.១៨២ ស/កទឹកល្អក់២ ខ.ទួលគោក | ១០៨៧៧០០ | ១៩៩៦<br>១៩៩៧<br>១៩៩៨<br>១៩៩៩ | សេវាកម្ម | ឆេង ទី |
| ១៩៦ | លីចេន ហ្គារមេន | ផ.៥ ស/កឫស្សីកែវ ខ.ឫស្សីកែវ | ១០០៨៦៣៤ | ២០០១ | ឧស្សាហកម្ម | TSAI CHU HO |
| ១៩៧ | កុងទីណង់តាល់ ឥណ្ឌូចិន | ២៨ ផ.៤៧ ស/កវត្តភ្នំ ខ.ដូនពេញ | ១០៦០៤៣៩ | ១៩៩៨<br>១៩៩៩<br>២០០០ | លក់ប្រេងឥន្ធនៈ | សាម ភព ឆាឡៅ |
| ១៩៨ | អាតិច | ១៦០ A ផ.ព្រះនរោត្តម ស/កចតុមុខ ខ.ដូនពេញ | ១០៨៣០៧៩ | ១៩៩៧<br>១៩៩៨<br>១៩៩៩ | ពាណិជ្ជកម្ម | វ៉ាន់ មុន |
| ១៩៩ | ណាតូរ៉ល ខេមបូឌា | ផ.មុនីរ៉េត ស/កស្ទឹងមានជ័យ ខ.មានជ័យ | ១០៦៥១៨០ | ១៩៩៨<br>១៩៩៩ | ឧស្សាហកម្ម | ស៊ិន ស៊ុយរ៉ុង |
| ២០០ | សំភារៈកសិកម្ម | ៣៩៤ ផ.មុនីវង្ស ស/កបឹងកេងកង១ ខ.ចំការមន | ១០៨០៧៦៩ | ២០០០ | អាហារ័ណ ទីហារ័ណ | ជ័យ សារង្ស |
| ២០១ | ប៊ុន ច័ន្ទ អាហារ័ណ ទីហារ័ណ សំណង់ | ៩៥២ ផ.១៦៣ ស/កបឹងកេងកង២ ខ.ចំការមន | ១០២២២២១ | ១៩៩៦ | [illegible] | [illegible] ច័ន្ទ |
| ២០២ | ប៉េង ហួត ពាណិជ្ជ អាហារ័ណ ទីហារ័ណ | ១៤០ B ផ.២៥៣ ស/កទឹកល្អក់១ ខ.ទួលគោក | ១០៦០៤១៧ | [illegible] | [illegible] | [illegible] |
| ២០៣ | អ៊ីម វី អ័រ អាហារ័ណ ទីហារ័ណ | ៤២ ផ.៤០២ ស/កទំនប់ទឹក ខ.ចំការមន | ១០៦២៤០០ | [illegible] | សេវាកម្ម | [illegible] |

| | | | | | | |
|---|---|---|---|---|---|---|
| ២០៤ | សណ្ឋាគារ រីហ្សិន | ៧ ផ.១០៩ ស/កបឹងរាំង ខ.ដូនពេញ | ១០៨០៥៥០ | ១៩៩៥-<br>១៩៩៧<br>១៩៩៨ | ពាណិជ្ជកម្ម | វឿន សានតូ |
| ២០៥ | រ៉ាលីម៉ិច | ១៦៤ ផ.ព្រះសីហនុ ស/កបឹងកេងកង២ ខ.ចំការមន | ១០៨១៧៤៨ | ១៩៩៥ | ពាណិជ្ជកម្ម | ឡេង ភ័យនី |
| ២០៦ | អ៊ិនធើណេស្សូណល ខនស៊ូលធិន ស៊ីរិស | ៧៧ DE, ផ.សម្តេចសុធារស | ១០៨១៨៨០ | ១៩៩៦ | ពាណិជ្ជកម្ម | លឹម ប៉ូឡាយ |
| ២០៧ | មាន ហុង | ៥១ ផ.៣១០ ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០៨២២៤៣ | ១៩៩៧ | ពាណិជ្ជកម្ម | មាន ហុង |
| ២០៨ | ហេភី ហូមហ្វ័រនី នីហ័រណ អាហ័រណ | ១៣៧ ABE, ផ.២៤៥ ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០៨២៤៣០ | ១៩៩៧ | ពាណិជ្ជកម្ម | ត្រាន់ ស៊ុមយៀង |
| ២០៩ | លីវ ស៊ាវ អ៊ិនធើណេស្សូណល | ៨២ ផ.មុនីរ៉េត ស/កទួលស្វាយព្រៃ១ ខ.ចំការមន | ១០៨២៩៩១ | ១៩៩៧-<br>២០០១ | ពាណិជ្ជកម្ម | អ៊ូង ជីវឡាយ |
| ២១០ | ឃី ចាន់ណា សំណង់ | ១៣៨ E, ផ.១២៨ ស/កមនោរម្យ ខ.៧មករា | ១០៨៣៣២១ | ១៩៩៩<br>២០០០ | ពាណិជ្ជកម្ម | តាន់ ចាន់ណា |
| ២១១ | តាំង លី អាហ័រណ នីហ័រណ | ៧៥ ផ.២២៥ ស/កផ្សារដេប៉ូ៣ ខ.ទួលគោក | ១០៨៤៤៩៨ | ១៩៩៩ | ពាណិជ្ជកម្ម | ឃឹម សាឃឿន |
| ២១២ | ហ្វ្រូវីង អ៊ិចប្រេស ស្ព័រថេហ្សិន | ៩៥ BE, ផ.២២ ស/កផ្សារដេប៉ូ៣ ខ.ទួលគោក | ១០៨២១១៤ | ១៩៩៩ | ពាណិជ្ជកម្ម | ទ្រឿង ចេវ៉ន |
| ២១៣ | ជោវលីង | ៣៨ ABE, ផ.១៩ ស/កចតុមុខ ខ.ដូនពេញ | ១០៨៧៣៦៩ | ២០០០ | សេវាកម្ម | ពៅ ឆវី |
| ២១៤ | ប្លូផេស៊ីហ្វិក អ៊ិចប្រេស | ១០៤ B ផ.សុធារស ស/កចតុមុខ ខ.ដូនពេញ | ១០៨៨៧១១ | ២០០០ | ពាណិជ្ជកម្ម | អៀម រាយ |
| ២១៥ | ហ៊ួ ប៉េងឡុង | ៨៣ E, ផ.២៨៦ ស/កអូរឡាំពិក ខ.ចំការមន | ១០៨៩៣៨៥ | ១៩៩៩ | ពាណិជ្ជកម្ម | ហ៊ួ ប៉េងឡុង |

បញ្ជីរាយនាមក្រុមហ៊ុនជំពាក់បំណុលពន្ធ ហើយបាត់ខ្លួនរកមិនឃើញមានបិទផ្សាយនៅនាយកដ្ឋានពន្ធដារ ដែលមានអាស័យដ្ឋានតាំងនៅកែងផ្លូវ៦៣ និងផ្លូវ២២៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សង្ឃឹម និង ជឿជាក់ថា លោក-លោកស្រី ជាប្រធាន អភិបាល ឬ បណ្ណាធិការ ដែលទទួលខុសត្រូវក្រុមហ៊ុន ដូចមានឈ្មោះក្នុងបញ្ជីរាយនាមខាងលើ ពិតជារួសរាន់អញ្ជើញមកជួបដោះស្រាយ ទូទាត់បំណុលពន្ធអោយបានចប់សព្វគ្រប់តាមការកំណត់ជាមិនខានឡើយ ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥ ៧-០២-២០៣ ប្រ.ក

# ប្រកាស
## ស្តីពី
## និតិវិធីជាបទដ្ឋានសំរាប់សកម្មភាពកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០២០២/០៣៤ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមការឯកភាពរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០០២

## សំរេច

**ប្រការ ១.-**

កំណត់និតិវិធីជាបទដ្ឋានសំរាប់សកម្មភាពកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា តទៅនេះហៅថាគ្រឹះស្ថានហិរញ្ញវត្ថុ ដោយបង្កើតជាមុននូវបទដ្ឋានសំរាប់ការអនុវត្តនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងដើម្បីអនុវត្តការត្រួតពិនិត្យប្រកបដោយការឯកភាព និងភាពត្រឹមត្រូវ ។

**ប្រការ ២.-**

១. "សកម្មភាពកែតម្រូវបន្ទាន់" គឺជាទណ្ឌកម្មខាងវិន័យ និងការដាក់កំហិតជាផ្លូវការ សំរាប់អនុវត្តចំពោះគ្រឹះស្ថានហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

២. "អនុបាតសាធនភាព" គឺជាអនុបាតដែលត្រូវបានគណនាតាមប្រកាសលេខ ធ៧.០០-៤៦ ប្រកស្តីពីអនុបាតសាធនភាពរបស់ធនាគារ ។

៣. "ផែនការស្តារដើមទុន" គឺជាផែនការផ្លូវការចុះហត្ថលេខាដោយក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន ហិរញ្ញវត្ថុ ហើយត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា ។ ផែនការនេះត្រូវចែងលំអិតពីសកម្មភាពយុទ្ធសាស្ត្រ និងការសន្យាដែលក្រុមប្រឹក្សាភិបាលត្រូវអនុវត្ត ដើម្បីសម្រេចអោយបានដើមទុនគ្រប់គ្រាន់តាមអនុបាតសាធនភាព ។ ផែនការនេះត្រូវមានចែងផងដែរ នូវគោលដៅហិរញ្ញវត្ថុជាតួលេខ និងកាលវិភាគដើម្បីសម្រេចឱ្យបាននូវគោលដៅនោះ ។

៤. "អភិបាលបណ្តោះអាសន្ន" គឺជាបុគ្គលដែលបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ស្របតាមមាត្រា ៥៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងដឹកនាំ និង ជាតំណាងអោយគ្រឹះស្ថានហិរញ្ញវត្ថុ ។ បុគ្គលដែលបានតែងតាំងមានកាតព្វកិច្ចត្រូវវាយតំលៃស្ថានភាពហិរញ្ញវត្ថុ និងគ្រប់គ្រងសកម្មភាពបច្ចុប្បន្ន ដើម្បីការពារអោយបាននូវសាធនភាពរបស់អង្គភាពចំណុះច្បាប់ និងរក្សាសិទ្ធិអ្នកផ្ញើរប្រាក់ និងឥណទាយក ។

៥. "ការប្រជុំអំពីដើមទុន" គឺជាការប្រជុំផ្លូវការរៀបចំដោយធនាគារជាតិនៃកម្ពុជា ដើម្បីជូនដំណឹងដល់នាយកនៃគ្រឹះស្ថានហិរញ្ញវត្ថុ អំពីកង្វះខាតដើមទុនធ្ងន់ធ្ងរនៅគ្រឹះស្ថានហិរញ្ញវត្ថុរបស់ខ្លួន និងអំពីកាលវិភាគជាក់លាក់សំរាប់បង្កើនដើមទុន ។

## ប្រការ ៣.-

តាមនិតិវិធីសកម្មភាពកែតម្រូវបន្ទាន់ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបែងចែកជាប្រភេទដោយផ្អែកលើអនុបាតសាធនភាពរបស់ខ្លួន ដូចបានកំណត់ក្នុងប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ ។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវ បានចាត់ថា ÷

ក. មានដើមទុនល្អប្រសើរ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ២៥ភាគរយ

ខ. មានដើមទុនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ២០ភាគរយ ប៉ុន្តែស្ថិតនៅក្រោម២៥ភាគរយ

គ. មានដើមទុនមិនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ១៥ភាគរយ ប៉ុន្តែស្ថិតនៅក្រោម ២០ភាគរយ

ឃ. ខ្វះដើមទុនច្រើន នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ៥ភាគរយ ប៉ុន្តែស្ថិតនៅក្រោម១៥ភាគរយ

ង. ខ្វះដើមទុនធ្ងន់ធ្ងរ នៅពេលអនុបាតសាធនភាពរបស់ខ្លួននៅក្រោម៥ភាគរយ ។

**ប្រការ ៤.-**

នៅពេលចាប់ផ្តើមមានដើមទុនមិនគ្រប់គ្រាន់ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវមានកាតព្វកិច្ចរៀបចំ និងដាក់ជូនផែនការស្តារដើមទុនមកធនាគារជាតិនៃកម្ពុជាឱ្យបានក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលដើមទុនមានមិនគ្រប់គ្រាន់ ។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងដល់គ្រឹះស្ថានហិរញ្ញវត្ថុជាលាយល័ក្ខណ៍អក្សរពីការយល់ព្រមទទួលយកបានផែនការស្តារដើមទុន ក្នុងរយៈពេល៣០ថ្ងៃគិតពីថ្ងៃទទួល ឬពីការយឺតយ៉ាវ និងមូលហេតុនៃការយឺតយ៉ាវ ។

**ប្រការ ៥.-**

ផែនការស្តារដើមទុនដែលអាចទទួលយកបាន ត្រូវបង្ហាញឱ្យឃើញពីលទ្ធភាពអនុវត្តបានការស្តារដើមទុន និងត្រូវមាន ÷

ក. តារាងតុល្យការនិងថវិកាបច្ចុប្បន្ន គំរោងថវិការយៈកាលវែង ផែនការជាយុទ្ធសាស្ត្រ ការវិភាគស្ថានភាពទីផ្សារដោយផ្អែកលើការសន្មតប្រាកដនិយម និងពត៌មានពាក់ព័ន្ធផ្សេងទៀត ។

ខ. មធ្យោបាយសំរាប់អនុវត្តការស្តារដើមទុន ត្រូវរៀបរាប់ផងដែរអំពី ÷

- ជំហានដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវអនុវត្តសំដៅបង្កើនដើមទុនឱ្យបានគ្រប់គ្រាន់ឡើងវិញ
- កំរិតនៃដើមទុនដែលត្រូវសំរេចឱ្យបានរៀងរាល់ត្រីមាសនៃឆ្នាំផែនការនិមួយៗ
- ប្រភេទនិងកំរិតនៃសកម្មភាពដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវប្រតិបត្តិ
- ពត៌មានដទៃទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៦.-**

ក្រៅពីការរៀបចំនិងដាក់ជូនផែនការស្តារដើមទុនមកធនាគារជាតិនៃកម្ពុជា ភាគទុនិកមានឥទ្ធិពលត្រូវធានាជាលាយល័ក្ខអក្សរថា គ្រឹះស្ថានហិរញ្ញវត្ថុនោះនឹងបំពេញកាតព្វកិច្ចក្នុងការអនុវត្តន៍ផែនការស្តារដើមទុន ។ ការធានានេះត្រូវមានរៀបរាប់អំពីកាតព្វកិច្ចហិរញ្ញវត្ថុរបស់ភាគទុនិកមានឥទ្ធិពលក្នុងការអនុវត្តន៍ផែនការស្តារដើមទុន។ ក្រៅពីនេះ ការធានាក៏ត្រូវមានការសន្យាថាម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុនឹង ÷

ក. ចាត់វិធានការណ៍ដែលតម្រូវដោយផែនការស្តារដើមទុន

ខ. ធានាជ្រើសរើសអ្នកគ្រប់គ្រងថ្មីមានសមត្ថភាព

គ.រឹតត្បិតប្រតិបត្តិការរវាងគ្រឹះស្ថានហិរញ្ញវត្ថុជាមួយបុគ្គលដែលជាម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុនោះ

ឃ. បញ្ឈប់សកម្មភាពណាដែលមានហានិភ័យ ឬពុំមានលក្ខណៈសមស្រប ។

អាស្រ័យទៅលើក្រុមហ៊ុនដែលពាក់ព័ន្ធ ការធានាត្រូវមានប័ណ្ណសងតាមបញ្ជា ការដាក់បញ្ចាំទ្រព្យសម្បត្តិ ការអះអាងដ៏សមស្របពីសាម្ភីក្រុមហ៊ុន សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងសកម្មភាពត្រួតពិនិត្យផ្សេងទៀតដែលធានាការអនុវត្តន៍ ។

**ប្រការ ៧.-**

គ្រឹះស្ថានហិរញ្ញវត្ថុមានដើមទុនមិនគ្រប់គ្រាន់ដែលមិនបានដាក់ជូន ឬមិនបានអនុវត្តផែនការស្តារដើមទុនដែលអាចទទួលយកបាន និងគ្រឹះស្ថានហិរញ្ញវត្ថុដែលខ្វះដើមទុនច្រើន ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យដូចខាង ក្រោមនេះ ÷

ក. ត្រូវមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា មុនពេលបើកប្រាក់រង្វាន់ ឬមុនពេលបង្កើនប្រាក់កំរៃជូនដល់អ្នកគ្រប់គ្រងជាន់ខ្ពស់

ខ. ត្រូវបញ្ជាអោយបំពេញដើមទុនឡើងវិញ

គ. ត្រូវមានការដាក់កំហិតលើប្រតិបត្តិការជាមួយបុគ្គលសម្ព័ន្ធ

ឃ. ត្រូវមានការដាក់កំហិតលើអត្រាការប្រាក់ចំពោះប្រាក់បញ្ញើ ។

វិធានការប្រកបដោយឆន្ទានុសិទ្ធិផ្សេងទៀត ក៏អាចសំរេចដោយឯកច្ឆ័ន្ទពីធនាគារជាតិនៃកម្ពុជា

ក. តម្រូវអោយរិតត្បិតមិនអោយមានកំណើនទ្រព្យសកម្ម ឬ តម្រូវឱ្យកាត់បន្ថយទ្រព្យសកម្មសរុប

ខ. តម្រូវអោយរិតត្បិតសកម្មភាពអាជីវកម្ម

គ. តម្រូវឱ្យលាលែងពីតំណែងនាយកប្រតិបត្តិមួយឬច្រើន

ឃ. បញ្ជាឱ្យជួលអ្នកគ្រប់គ្រងជាន់ខ្ពស់ថ្មីដែលមានគុណវុឌ្ឍិគ្រប់គ្រាន់

ង. បញ្ជាអោយបញ្ឈប់ការទទួលប្រាក់បញ្ញើពីធនាគារទំនាក់ទំនង

ច. បញ្ជាឱ្យដកខ្លួនចេញពីបុគ្គលសម្ព័ន្ធ ដែលបណ្តាលឱ្យមានហានិភ័យខ្ពស់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ

ឆ. តែងតាំងអភិបាលបណ្តោះអាសន្ន ។

**ប្រការ ៨.-**

នៅពេលដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានដឹងថាខ្វះដើមទុនធ្ងន់ធ្ងរ ត្រូវកោះប្រជុំអំពីដើមទុន ។

គ្រឹះស្ថានហិរញ្ញវត្ថុដែលខ្ចះដើមទុនផ្ទាល់សុទ្ធមិន អាចធ្វើសកម្មភាពដូចខាងក្រោមបានឡើយ ÷

ក. លក់ទ្រព្យសកម្មយ៉ាងច្រើន ឬបដិសេធការធានារបស់អតិថិជន

ខ. ផ្តល់ឥណទានថ្មីចំពោះអតិថិជន

គ. កែប្រែវិធីគណនេយ្យ លើកលែងតែវិធីនេះមិនស្របតាមច្បាប់

ឃ. បើកប្រាក់កំរៃ ឬ ប្រាក់រង្វាន់

ង. ផ្តល់ការប្រាក់លើទ្រព្យអកម្មខ្ពស់ជាងអត្រាទីផ្សារ ។

អភិបាលបណ្តោះអាសន្នត្រូវបានតែងតាំងក្នុងរយៈពេល ១៨០ ថ្ងៃ បន្ទាប់ពីបានជូនដំណឹងពីការប្រជុំអំពីដើមទុន ។

**ប្រការ ៩.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

រាជធានីភ្នំពេញ, ថ្ងៃទី១៧ខែតុលា ឆ្នាំ ២០០២

**ទេសាភិបាល**

**ជា-ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B-7-02-203 P-K

# PRAKAS
## on
## Standardized Procedure for Prompt Corrective Action for Banking and Financial Institutions

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions
- With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency **Chea Chanto** as Governor General of the National Bank of Cambodia
- Pursuant to the agreement of the senior officer meeting of the National Bank of Cambodia on September 09, 2002.

**Decides**

**Article 1.**

To issue formal procedure for prompt corrective action (PCA) of the banking and financial institutions licensed by the National Bank of Cambodia, hereafter referred to as financial institutions by pre-establishing practice formalities of financial institutions and to implement oversights with uniformity and fairness.

**Article 2.**

1. "Prompt corrective action" is a prescribed set of disciplinary sanctions and limitations applicable to financial institutions in accordance to the Law on Banking and Financial Institutions.

2. "Solvency ratio" refers to the calculation of capital adequacy stipulated in Prakas B 7-00-46 relating to the Banks' Solvency ratio.

3. "Capital Restoration Plan" is a formal plan signed by a financial institution's Board of Directors and submitted to the National Bank of Cambodia. Such a plan details the actions, strategies and commitments the Board will undertake to attain capital adequacy as defined by the solvency ratio. Such a plan includes numerical financial goals and stipulates timetables and deadlines for attaining said benchmarks.

4. "Provisional Administrator" is a person appointed by the National Bank of Cambodia following art. 57 of the law on banking and financial institutions (LBFI) to manage, direct and represent the financial institution. His duty (art. 59 of LBFI) is to assess the financial situation and administer the current activities in order to preserve as far as possible the covered entity's solvency and maintain the rights of depositors and creditors.

5. "Capital Call Meeting" is a formal meeting called by NBC, where financial institution directors are notified of a material capital deficiency at their financial institution and given a specified time period to provide a specific capital Injuction amount.

**Article 3.**

Under the prompt corrective action procedures, the financial institutions will be categorized based on their solvency ratio, as previously defined in Prakas on Solvency ratio of Banks. A financial institution is classified as:

a. Well-Capitalized when its solvency ratio equals or exceeds 25 per cent.

b. Adequately Capitalized when its solvency ratio equals or exceeds 20 per cent, but is less than 25 per cent

c. Undercapitalized when its solvency ratio equals or exceeds 15 per cent, but is less than 20 per cent

d. Significantly Undercapitalized when its solvency ratio equals or exceeds 5 per cent., but is less than 15 per cent.

e. Critically Undercapitalized when its solvency ratio is less than 5 per cent.

**Article 4.**

When a financial institution becomes undercapitalized, it must prepare and submit a Capital Restoration Plan (CRP) to the NBC within 30 days after it became undercapitalized. The NBC will notify the financial institution in writing of the CRP's acceptability within 30 days of receipt or any delay and the reason for the delay.

**Article 5.**

An acceptable CRP must indicate the possibility of capital restoration and must include the following:

a. Current balance sheets and budgets, long-term budgets, a strategic plan, market analysis based on realistic assumptions, and any other relevant information.
b. Means to raise capital that must address:

- The steps the financial institution will take to become adequately capitalized.
- The levels of capital to be attained during each quarter of each year of the plan.
- The types and levels of activities in which the financial institution will engage.
- Any other information the NBC may require.

**Article 6.**

In addition to the preparation and submission of the CRP to the NBC, the influential shareholders must submit a written guarantee that the financial institution will comply with the CRP. The guarantee must include the financial commitment of the influential shareholders in the implementation of the CRP. In addition, the guarantee must include the assurances that the owner will:

a. Take actions required by the CRP.

b. Ensure the selection of new competent management.

c. Restrict transactions between the financial institution and the owner.

d. Discontinue any risky or inappropriate activities.

Depending on the company involved, the guarantee may also include a promissory note, a pledge of assets, appropriate assurances from company counsel, a company board of directors' resolution, and other supervisory actions deemed necessary to ensure performance.

**Article 7.**

Undercapitalized financial institutions that fail to submit or implement an acceptable CRP and significantly undercapitalised financial institutions shall face the following sanctions:

a. NBC approval before paying any bonus or increasing compensation to a senior executive officer.

b. Injunction to recapitalise

c. Restrictions on transactions with affiliates.

d. Restrictions on interest rates on deposits

Other discretionary measures may also be decided, at NBC's sole decision:

a. Restrictions on asset growth or reduction of assets.

b. Restriction on activities.

c. Resignation of one or more executives

d. Injunction to hire new qualified senior executive officers

e. Injunction to stop taking deposits from correspondent financial institutions.

f. Injunction of divesting subsidiaries that may cause a significant risk to the financial institution

g. Appointment of a provisional administrator

**Article 8.**

As soon as a financial institution is known to have become critically undercapitalized, a capital call meeting shall be called.

The financial institution shall be ordered not to:

a. Sell significant assets or waiver customers guarantees

b. Extend new credits to customers

c. Change accounting methods, unless existing ones break the law

d. Pay compensation or bonuses.
e. Pay interest on liabilities above prevailing market rates.

A provisional administrator shall be appointed within 180 days of notifying capital call meeting.

**Article 9.**

The General Direction, the General Secretariat, the General Cashier, the General Inspection, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the NBC's supervisory authority shall implement this Prakas.

**Article 10.**

This Prakas shall have effect from the signing date.

Phnom Penh, 17 October 2002
**The Governor**

cc: - The Members of the Board of Directors
- The parties concerned as stated in Article 9
- File
- CM "for info"
- Administration of CM
"for publication in thc National Gazcttc"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២-២០៦ ប្រ.ក.

# ប្រកាស
## ស្តីពី
## និតិវិធីជាបទដ្ឋានសំរាប់ការកំណត់អត្តសញ្ញាណនៃការសំអាតប្រាក់ នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០២០២/០៤៨ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## សំរេច

**ប្រការ ១.-**

កំណត់នីតិវិធីជាបទដ្ឋានសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា តទៅនេះហៅថាគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការធ្វើស្វ័យត្រួតពិនិត្យរបស់អតិថិជន និងសំរាប់កំណត់អត្តសញ្ញាណនៃការសំអាតប្រាក់ ។

**ប្រការ ២.-**

គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវបង្កើត គ្រប់គ្រងនិងរក្សាទុកកម្មវិធីមួយដែលធានានិងតាមដានអោយ

មានប្រសិទ្ធភាពនូវសកម្មភាពប្រឆាំងការសំអាតប្រាក់ដែលត្រូវអនុវត្តតាមប្រកាសនេះ ។ កម្មវិធីអនុវត្តផ្ទៃក្នុងរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវសរសេរជាលាយលក្ខណ៍អក្សរបានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាលដោយមានកំណត់ហេតុប្រជុំ ។ គោលនយោបាយនេះត្រូវរួមមាន ÷

- ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដើម្បីធានាការអនុវត្តន៍ជាប្រចាំ
- ការសាកល្បងដោយឯករាជ្យបញ្ជាក់ពីការអនុវត្តន៍
- ការសម្របសម្រួលនិងការតាមដានពិនិត្យប្រចាំថ្ងៃ ដោយបុគ្គលិក១រូបដែលបានតែងតាំង
- ការបណ្តុះបណ្តាលបុគ្គលិក ។

**ប្រការ ៣.-**

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ចំពោះអត្តសញ្ញាណរបស់អតិថិជន ។ ការបើកគណនីអនាមិកត្រូវបានហាមឃាត់ជាដាច់ខាត ។ ត្រូវរិតត្បិតចំពោះក្រុមហ៊ុនដែលបានបើកគណនីហើយពុំមានសកម្មភាព ។ ចំពោះអតិថិជនជាក្រុមហ៊ុនត្រូវសំគាល់អត្តសញ្ញាណភាគទុនិកអោយបានច្បាស់លាស់ និងជាអចិន្ត្រៃយ៍ ។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវផ្អែកលើអត្តសញ្ញាណរបស់អតិថិជន ដែលមាននៅលើឯកសារផ្លូវការបើមិនទាន់បានស្គាល់អតិថិជនពីមុនមកទេ ។

**ប្រការ ៤.-**

ដើម្បីធានាអោយប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាព គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបង្ហាញនូវការប្តេជ្ញាអនុវត្តដោយបង្កើតគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់មួយរួមមាន : ការបើកគណនី ការតាមដានត្រួតពិនិត្យ និងនីតិវិធីរាយការណ៍អំពីរូបិយវត្ថុដោយផ្ញើជូនទៅអ្នកគ្រប់គ្រងជាន់ខ្ពស់ជាប្រចាំ ។

**ប្រការ ៥.-**

ស្នងការគណនីឯករាជ្យ ឬអ្នកត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានហិរញ្ញវត្ថុត្រូវ ÷

១.បង្ហាញពីភាពសុចរិតនិងប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រង និងការអនុវត្តន៍ប្រកាសនេះ

២.សាកល្បងលើប្រតិបត្តិការគ្រប់ផ្នែកប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ពិសេសផ្នែកដែលមានហានិភ័យខ្ពស់ ផលិតផល និងសេវាកម្ម

៣.វាយតម្លៃលើភាពគ្រប់គ្រាន់នៃវិធីសាស្ត្ររបស់គ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីរកអោយឃើញសកម្មភាពសង្ស័យ ។

**ប្រការ ៦.-**

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវកត់ត្រា និងរក្សាទុកឯកសារសំរាប់រយៈពេល១០ឆ្នាំ នូវរាល់ប្រតិបត្តិការណាដែលស្មើឬលើសពី៤០លានរៀល ឬជារូបិយប័ណ្ណផ្សេងទៀតដែលមានតំលៃស្មើ ។ ប្រតិបត្តិការច្រើនលើកត្រូវបានចាត់ថាជាប្រតិបត្តិការតែមួយ ប្រសិនបើប្រតិបត្តិការទាំងនេះត្រូវបានធ្វើជាផលប្រយោជន៍ចំពោះបុគ្គលតែមួយ ។

**ប្រការ ៧.-**

គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ចំពោះប្រតិបត្តិការសង្ស័យណាដែលពាក់ព័ន្ធនឹងការរំលោភច្បាប់ ឬបទបញ្ញត្តិ ។ ការផ្តល់ពត៌មានពីរបាយការណ៍សកម្មភាពសង្ស័យទៅអោយអតិថិជនត្រូវបានបរាមឃាត់ដាច់ខាត ។

**ប្រការ ៨.-**

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធានាបណ្តុះបណ្តាលជាប្រចាំនូវបុគ្គលិកទាំងអស់ រួមទាំងអ្នកគ្រប់គ្រងជាន់ខ្ពស់អំពីបញ្ញត្តិរបស់ប្រកាសនេះ ព្រមទាំងគោលនយោបាយនិងនីតិវិធីផ្ទៃក្នុងដើម្បីប្រឆាំងការសំអាតប្រាក់។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធ្វើវិសោធនកម្មលើកិច្ចសន្យាការងារឯកត្តជននិងបទបញ្ជាផ្ទៃក្នុងដើម្បីធានាការពារ ជាពិសេសចំពោះនិយោជិកដែលត្រូវធ្វើរបាយការណ៍មកធនាគារជាតិនៃកម្ពុជាតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ ៩.-**

ការខកខានមិនអនុវត្តបានត្រឹមត្រូវតាមបញ្ញត្តិណាមួយនៃប្រកាសនេះ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវទទួលរងនូវទណ្ឌកម្មដូចមានចែងនៅមាត្រា៥២ និង៥៥ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ១០.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្ត មឹុងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ១១.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

**ទេសាភិបាល**

ជា-ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B.7.02 – 206 Prokor

# Prakas
on
# Standardized Procedure for Identification of Money Laundering at the Banking and Financial Institutions

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions
- With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia
- Pursuant to the request of the Directorate General

## decides

**Article 1.**

To issue a standardized procedure to assist all banks and financial institutions licensed by the National Bank of Cambodia hereafter referred to as financial institutions in self-monitoring for potential client money laundering and for the identification of money laundering.

**Article 2.**

All financial institutions must develop, administer, and maintain a policy that ensures and monitors an effective action against money laundering compliant with the present prakas. A financial institution's internal compliance policy must be written, approved

by the board of directors, and noted as such in the board meeting minutes. The policy must include:

- A system of internal controls to ensure ongoing compliance.
- Independent testing of compliance.
- Daily coordination and monitoring of compliance by a designated person.
- Training of personnel.

**Article 3.**

Financial institutions shall pay attention to customers' identification. Opening anonymous accounts shall be prohibited. Opening accounts for non-active companies shall be restricted and submitted to precise and permanent identification of shareholders. Unless customers have been known for years, financial institutions shall base identification of customers on official documents.

**Article 4.**

To ensure an effective system of internal controls, a financial institution shall establish a comprehensive policy and set of controls, including account opening, monitoring, and currency reporting procedures, and the senior management must be kept informed.

**Article 5.**

The financial institution's internal or external auditors must be able to:

1. Attest to the overall integrity and effectiveness of management systems and controls, and prakas technical compliance.
2. Test transactions in all areas of the financial institution with emphasis on high-risk areas, products, and services.
3. Assess adequacy of the financial institution's process for identifying suspicious activity.

**Article 6.**

The financial institutions are required to maintain records for a period of ten years for each transaction in currency of *more than KHR* 40,000,000 or equivalent. Multiple currency transactions must be treated as a single transaction if they are conducted for the interest of the same person.

**Article 7.**

All financial institutions are required to submit promptly to the NBC for any suspicious transaction relevant to a possible violation of law or regulation. Informing customers for the issuance of a SAR shall be strictly prohibited.

**Article 8.**

Financial institutions must ensure that appropriate personnel including senior management are trained in all aspects of the regulatory requirements of the present prakas and internal anti-money laundering policies and procedures. Individual work contracts and financial institutions internal regulations shall be amended so as to ensure special protection for employees reporting to NBC following the present prakas

**Article 9.**

Failure to comply with any of the provisions included in the present prakas shall make the financial institutions subject to sanctions and penalties as per article 52 and 55 of the law on banking and financial institutions.

**Article 10.**

The General Direction, the General Secretariat, the General Cashier, the General Inspection, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the NBC's supervisory authority shall implement this Prakas.

**Article 11.**

The present prakas shall have effect from the signing date

Phnom Penh, 21 / 10 / 2002
**The Governor**

cc: - The Members of the Board of Directors
- The parties concerned as stated in Article 10
- File
- CM "for info"
- Administration of CM
"for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០០២ សរ.ស

ភ្នំពេញ,ថ្ងៃទី១៨ ខែ១៧ឆ្នាំ២០០២

# សារាចរណែនាំ

កន្លងទៅនេះ ក្រសួងមហាផ្ទៃពិនិត្យឃើញថា ការប្រើប្រាស់វិទ្យុទាក់ទងគ្រប់ប្រភេទ នៅតាមបណ្ដា ក្រុមហ៊ុនឯកជន និងជនស៊ីវិលមានលក្ខណៈច្របូកច្របល់ និងបំពានទៅលើការកំណត់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាពិសេសបានបង្កការរំខានយ៉ាងខ្លាំងដល់ការប្រើប្រាស់រលកធាតុអាកាស របស់កងកម្លាំងមានសមត្ថកិច្ច ។

នៅពេលខាងមុខនេះ ព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសដ៏ឧត្តុងឧត្តម ក្នុងការរៀបចំវេទិការ អន្តរជាតិជាច្រើន ដែលមានអត្ថន័យនយោបាយជាប្រវត្តិសាស្ត្រ ។ ទន្ទឹមនោះពិធីបុណ្យជាតិផ្សេងៗ ក៏ត្រូវប្រារព្ធធ្វើជាបន្តបន្ទាប់នៅក្នុងទូទាំងប្រទេស ។

ដើម្បីបង្កលក្ខណៈឱ្យកងកម្លាំងមានសមត្ថកិច្ច មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចការពារ សន្តិសុខ សណ្ដាប់ធ្នាប់ និងមិនមានការបង្ករការរំខានក្នុងការទាក់ទងគ្នាតាមរលកធាតុអាកាស ។

ក្រសួងមហាផ្ទៃធ្វើការណែនាំដល់អង្គភាពជំនាញ និងស្នងការដ្ឋាននគរបាលខេត្ត-ក្រុងដូចខាង ក្រោម :

១-អង្គភាពជំនាញ និងស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ត្រូវសហការជាមួយមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ជូនដំណឹងទៅបណ្ដាក្រុមហ៊ុនឯកជន និងជនស៊ីវិលដែលបានចុះបញ្ជីប្រើប្រាស់វិទ្យុទាក់ទង គ្រប់ប្រភេទអនុវត្តឱ្យបានត្រឹមត្រូវរលកធាតុអាកាសវិទ្យុ តាមការកំណត់របស់ស្ថាប័នប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

២-ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង សហការជាមួយស្ថាប័នប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរៀបចំគ្រប់គ្រងរលកធាតុអាកាសវិទ្យុ និងការប្រើប្រាស់ ហើយឱ្យអ្នកបច្ចេកទេសកាត់រលកធាតុ អាកាសវិទ្យុរបស់បណ្ដាក្រុមហ៊ុន និងជនស៊ីវិលមិនឱ្យចល័តបាន ។

៣-ត្រូវកំណត់រលកធាតុអាកាសវិទ្យុ របស់បណ្ដាក្រុមហ៊ុន និងជនស៊ីវិលមិនឱ្យជាន់គ្នា និងរលកធាតុអាកាសវិទ្យុ របស់កងកម្លាំងមានសមត្ថកិច្ចដែលបំពេញភារកិច្ចប្រចាំថ្ងៃ ។

៤-ក្នុងករណីក្រុមហ៊ុន ឬជនស៊ីវិលណាមួយ ដែលប្រើប្រាស់រលកធាតុអាកាសវិទ្យុ ធ្វើឱ្យប៉ះពាល់ ឬបង្កការរំខានដល់ការបំពេញភារកិច្ច របស់សមត្ថកិច្ច ត្រូវចាត់វិធានការដកហូតវិទ្យុទាក់ទងទាំងនោះរក្សាទុកជាបណ្ដោះអាសន្ន ។ ក្នុងករណីដែលមានចេតនាធ្វើឱ្យមានការប៉ះពាល់ដល់សន្តិសុខជាតិ ត្រូវចាត់វិធានការតាមផ្លូវច្បាប់ ។

៥-ផ្អែកតាមសារាចរណែនាំនេះ នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ត្រូវចាត់ចែងផែនការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

សហរដ្ឋមន្ត្រី

ស ខេង យូ.ហុកគ្រី

<u>ចម្លងជូន៖</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-ក្រសួងការពារជាតិ

-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

-អគ្គស្នងការដ្ឋាននគរបាលជាតិ

-ទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

-អភិបាលគ្រប់ខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៧៦៩ អយក.ប្រក

# ប្រ កា ស

ស្តីពីការបើកអនុវិទ្យាល័យ ពាមគ្រែង

ស្ថិតនៅក្នុងឃុំក្តីដូង ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំក្តីដូង ស្រុកស្ទឹងសែន ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## ស ម្រេ ច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថាៈ អនុវិទ្យាល័យ « ពាមគ្រែង » ស្ថិតនៅក្នុងឃុំក្តីដូង ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០២

**ឋ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

<u>**កន្លែងទទួល :**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ធំ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៧៧០ អយក.ប្រក

# ប្រ ក ា ស

ស្ដីពីការបើកអនុវិទ្យាល័យ ភ្នំព្រឹក

ស្ថិតនៅក្នុងឃុំពេជ្រចិន្ដា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្ដីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំពេជ្រចិន្ដា ស្រុកភ្នំព្រឹក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាព ពីមន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តបាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## ស ំ រេ ច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថាៈ អនុវិទ្យាល័យ « ភ្នំព្រឹក » ស្ថិតនៅក្នុងឃុំពេជ្រចិន្ដា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តបាត់ដំបង " ដើម្បីជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៧៧១ អយក.ប្រក

# ប្រកាស
## ស្តីពីការបើកអនុវិទ្យាល័យ តាគ្រាម
## ស្ថិតនៅក្នុងឃុំតាគ្រាម ស្រុកបាណន់ ខេត្តបាត់ដំបង

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំតាគ្រាម ស្រុកបាណន់ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា: អនុវិទ្យាល័យ « តាគ្រាម »ស្ថិតនៅក្នុងឃុំតាគ្រាម ស្រុកបាណន់ ខេត្តបាត់ដំបង ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តបាត់ដំបង " ដើម្បីជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៧៧៧ អយក.ប្រក

# ប្រ កា ស

ស្តីពីការបើកអនុវិទ្យាល័យ ពាមឯក

ស្ថិតនៅក្នុងឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់នាយកអនុវិទ្យាល័យពាមឯក លេខ ០៦២ អវ.ពឯ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដោយមាន យោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## ស ំ រ េ ច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថាៈ អនុវិទ្យាល័យ « ពាមឯក » ស្ថិតនៅក្នុងឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តបាត់ដំបង " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៩៧៣ អយក.ប្រក

# ប្រ កា ស

ស្តីពីការបើកអនុវិទ្យាល័យ គាស់ក្រឡ

ស្ថិតនៅក្នុងឃុំគាស់ក្រឡ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំគាស់ក្រឡ ស្រុកគាស់ក្រឡ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តបាត់ដំបង
- តាមសេចក្តីត្រូវការរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំ រេ ច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា . អនុវិទ្យាល័យ " គាស់ក្រឡ " ស្ថិតនៅក្នុងឃុំគាស់ក្រឡ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តបាត់ដំបង " ដើម្បីជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ៧៧៤ អយក.ប្រក

# ប្រ កា ស

ស្តីពីការបើកអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន អម្ពវ័នជំនីក

ស្ថិតនៅក្នុងឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡា លេខ ១៧២ អយក.កច_មស ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**ស ម្រេ ច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថាៈ អនុវិទ្យាល័យ « ប៊ុន រ៉ានី ហ៊ុន សែន អម្ពវ័នជំនីក » ស្ថិតនៅក្នុងឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ទ៊ុម_សិទ្ធិ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ចាម " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ៧៧៥ អយក.ប្រក

# ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ « សូបិណ » ទៅជាវិទ្យាល័យ « សូបិណ »

ស្ថិតនៅក្នុងឃុំរាមអណ្តើក ស្រុកគីរីវង់ ខេត្តតាកែវ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ក្នុងឃុំរាមអណ្តើក ស្រុកគីរីវង់ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « សូបិណ » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « សូបិណ » ស្ថិតនៅក្នុងឃុំរាមអណ្តើក ស្រុកគីរីវង់ ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ

**អ៊ឹម_សិទ្ធី**

<u>កន្លែងទទួល</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ "ដើម្បីជាពត៌មាន"
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Takev.doc